**UNITED NATIONS**
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

# ដំណើរឆ្ពោះទៅកាន់គោលនយោបាយពន្ធនាគារប្រកបដោយមនុស្សធម៌សំរាប់កម្ពុជា[១]

## ខែ វិច្ឆិកា ឆ្នាំ ២០០២

## សេចក្តីផ្តើម

ឯកសារនេះមានគោលបំណងផ្តួចផ្តើមការពិភាក្សាអំពីបញ្ហាពន្ធនាគារ ។ ឯកសារនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើបទពិសោធន៏របស់ការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ដែលបានធ្វើទស្សនកិច្ចពន្ធនាគារជាទៀងទាត់ ចាប់តាំងពីការិយាល័យ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៣ និងផ្អែកលើរបាយការណ៏របស់អង្គការក្រៅរដ្ឋាភិបាលនានា ។ ឯកសារនេះ សង្ខេបអំពីស្ថានភាពប្រែប្រួលនៅក្នុងពន្ធនាគារ ចាប់តាំងពីឆ្នាំ១៩៩៤មក ដែលពេលនោះការិយាល័យប្រចាំកម្ពុជា បានចេញផ្សាយនូវរបាយការណ៏មួយ ដែលមានចំណងជើងថា *ស្ថានភាពពន្ធនាគារនៅប្រទេសកម្ពុជា* ដែលបានកត់សំគាល់ ពីវិស័យដែលរីកចំរើន និងវិស័យដែលដុនដាប ។

របាយការណ៏នេះ បានដាក់ចេញជាអនុសាសន៏មួយចំនួន សំរាប់ធ្វើការពិភាក្សាអំពីវិធានការផ្សេង១ ដែលអាចចាត់ឡើង ដើម្បីធ្វើឱ្យស្ថានភាពពន្ធនាគារបច្ចុប្បន្នបានល្អប្រសើរឡើងថែមទៀត ។ គេអាចចាត់វិធានការខ្លះជាបន្ទាន់ ដូចជាការអនុវត្តន៏ច្បាប់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ពង្រឹងសិទ្ធិចូលសួរសុខទុក្ខអ្នកទោសនិងជនជាប់ចោទ ហើយនិងបញ្ឈប់ការអនុវត្តន៏មួយចំនួន ដូចជាការដាក់ខ្នោះអ្នកទោសជាដើម ។ វិធានការផ្សេងទៀតតម្រូវឱ្យមានការកែប្រែគោលនយោបាយ និងការលៃបំរុងធនធានបន្ថែមទៀតសំរាប់ផ្តល់ឱ្យពន្ធនាគារ ។

---

[១] អត្ថបទកែសំរួលនេះ ត្រូវបានពិភាក្សាជាមួយអាជ្ញាធរពន្ធនាគារ នៅក្នុងកម្មវិធីវេទិកាតុមូល ដែលមានការចូលរួមពីសំណាក់មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលនានា ។ កិច្ចពិភាក្សានេះ បានប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់លោកតំណាងពិសេស នៅក្នុងអំឡុងពេលធ្វើបេសកកម្មលើកទីប្រាំពីរ របស់លោកមកកាន់ប្រទេសកម្ពុជា កាលពីខែវិច្ឆិកា ឆ្នាំ២០០២ ។

#10. Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587
E-mail: cohchr@online.com.kh Internet: www.unhchr.ch/cambodia

តំណាងពិសេស នៃលោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាសង្ឃឹមថា ឯកសារពិភាក្សានេះ កំពុងមានការជឿនលឿនទៅមុខ នឹងសំគាល់ពីការចាប់ផ្តើមពិភាក្សាក្នុងន័យស្ថាបនានៅក្នុងប្រទេសកម្ពុជា អំពីគោលនយោបាយព្រហ្មទណ្ឌ និងលក្ខខណ្ឌនៃការដាក់ពន្ធនាគារ ។ ដូចជាប្រទេសដទៃទៀតដែរ គឺមានតែជនក្រីក្រទេដែលរងគ្រោះច្រើនជាងគេពីគោលនយោបាយ និងការអនុវត្តន៍បច្ចុប្បន្ននេះ ។ លោកតំណាងពិសេសជឿជាក់ថា សភាពការណ៍បច្ចុប្បន្ន គឺជាសភាពការណ៍មួយ ដែលគេអាចធ្វើឱ្យប្រសើរឡើងបាន និង ជឿជាក់ថា គោលនយោបាយនិងការអនុវត្តន៍ប្រកបដោយមនុស្សធម៌ចំពោះអ្នកទោសក្នុងពន្ធនាគម្ពុជា អាចនាំឱ្យមានប្រយោជន៍ដល់សង្គមកម្ពុជាទាំងមូល ។

**បញ្ហាចម្បងនានា**

- អ្នកទោសក្នុងពន្ធនាគារកម្ពុជា មានជម្ងឺរ៉ាំរ៉ៃ សុខភាពចុះខ្សោយ ខ្វះខាតម្ហូបអាហារ ទឹក និងអនាម័យ ដែលនេះគឺជាមូលហេតុចំបង ។
- ចំនួនអ្នកទោសច្រើនលើសចំណុះត្រូវបានឃុំខ្លួនជាបណ្តោះអាសន្នក្នុងពន្ធនាគាររង់ចាំសវនាការ អ្នកខ្លះត្រូវជាប់ឃុំឃាំងហួសរយៈពេលកំណត់ ហើយជារឿយៗ ពួកគេជាប់ចោទពីបទល្មើសតូចតាច ។
- ជារឿយៗ ជនជាប់ចោទត្រូវបានតុលាការបើកសវនាការកំបាំងមុខ និងដោយគ្មានមេធាវីការពារទៀតផង ជាពិសេស នៅតាមបណ្តាខេត្តនានានៃប្រទេសកម្ពុជា ។ នេះគឺជាការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្សរបស់អ្នកទោស និងជាការប្រព្រឹត្តកំហុសឆ្គងធ្ងន់ធ្ងរ ក្នុងកិច្ចដំណើរការរបស់តុលាការ ។
- តាមធម្មតា គេសង្កេតឃើញមានការដាក់ទោសធ្ងន់ ចំពោះបទល្មើសតូចតាច នៅខណៈដែលគេអាចផ្តន្ទាទោសតាមជំរើសផ្សេង ដែលមានលក្ខណៈសមរម្យជាង ។
- សិទ្ធិប្តឹងឧទ្ធរណ៍មានក៏រិតតិចតួចបំផុត បើតាមការអនុវត្តន៍ជាក់ស្តែង ។
- ការចូលសួរសុខទុក្ខអ្នកទោស និងពិរុទ្ធជន ដោយមេធាវី សមាជិកគ្រួសារ និងអង្គការសិទ្ធិមនុស្សនានាមានការរិតត្បិតខ្លាំង ។
- ជានិច្ចកាល ពិរុទ្ធជនត្រូវបានគេដាក់ឱ្យនៅលាយឡំគ្នាជាមួយនឹងទណ្ឌិត អ្នកទោសជាអនីតិជនជាមួយអ្នកទោសជានីតិជន ហើយអ្នកទោសបុរសជាមួយអ្នកទោសស្ត្រី ។

## ១_ ការដាក់អ្នកទោសច្រើនលើសចំណុះ និងអ្នកទោស

*របាយការណ៍អំពីស្ថានភាពពន្ធនាគារនៃប្រទេសកម្ពុជា* ត្រូវបានរៀបចំឡើង ផ្អែកតាមការសិក្សាស្រាវជ្រាវ ដែលជាផ្នែកមួយនៃការធ្វើទស្សនកិច្ចពន្ធនាគារយ៉ាងទៀងទាត់ នៅក្នុងខែមីនា រហូតដល់ខែ កក្កដា ឆ្នាំ១៩៩៤ ព្រមជាមួយនឹងការស៊ើបអង្កេតបន្ថែមទៀត រហូតដល់ខែវិច្ឆិកា ឆ្នាំ១៩៩៤។

**<u>ចំនួនអ្នកទោសកម្ពុជាទាំងអស់ ១៩៩៤-២០០២</u>**




របាយការណ៍ នេះក៏មានដាក់បញ្ចូលផងដែរ នូវការស្រាវជ្រាវមានកំណត់ ទៅលើអ្នកទោសចំនួន៨៥ នាក់ អំពីសភាពការណ៍ជុំវិញការឃុំឃាំង និងលក្ខខណ្ឌផ្សេងៗទៀត ដែលពួកគេបានជួបប្រទះនៅក្នុងពន្ធនាគារ។ របាយការណ៍នេះបានបង្ហាញថា នៅក្នុងខែកញ្ញា ឆ្នាំ១៩៩៤ មានអ្នកទោសសរុបទាំងអស់ ១៩៨១ នាក់ (រួមទាំងអ្នកទោស ស្ត្រីចំនួន ៩៣ នាក់ផងដែរ) ត្រូវបានគេដាក់ពន្ធនាគារស៊ីវិលចំនួន២៤ នៃប្រទេសកម្ពុជា[២]។ ចាប់តាំងពីពេលនោះ ចំនួនអ្នកទោសមានការកើនឡើងជិតបីដងគឺ៥៧៦០ នាក់ នៅក្នុងខែតុលា ឆ្នាំ២០០២។ បើប្រៀបធៀបចំនួនអ្នកទោសទៅនឹងអាត្រាប្រជាពលរដ្ឋដោយគិតចំនួនអ្នកទោស ក្នុងចំណោមប្រជាពលរដ្ឋ ១០០,០០០នាក់ ឃើញថាមានការកើនឡើងប្រហែលពី២២ ទៅ ៤៣នាក់ ទោះបីជាតួលេខនេះមានចំនួនទាបក៏ដោយ បើប្រៀបធៀបទៅនឹងមធ្យមភាគក៏រិតពិភពលោក ដែលបានប៉ាន់ប្រមាណគឺចំនួន ១៤០ នាក់ ក្នុងឆ្នាំ២០០១[២]។

---

[២] យោលទៅលើរបាយការណ៍ដែលមានទំនោរទៅរកប្រធានពន្ធនាគារនាពេលនោះ ដែលសរសេរបំផ្លើសចំនួនអ្នកទោស ដើម្បីបានទទួលថវិកាបន្ថែម ដូច្នេះហើយចំនួនពិតប្រាកដ នៃអ្នកទោសសរុបទាំងអស់ អាចមានចំនួនតិចជាងនេះ។

[២] ឧបករណ៍ស្តីពីការអភិវឌ្ឍន៍គោលការណ៍ពន្ធនាគារអន្តរជាតិ នៃមជ្ឈមណ្ឌលអន្តរជាតិ ដើម្បីកែទំរង់ច្បាប់ព្រហ្មទណ្ឌនិង គោលការណ៍យុត្តិធម៌ព្រហ្មទណ្ឌ ខែកក្កដា ២០០១។

បច្ចុប្បន្ននេះ ពន្ធនាគារមួយចំនួន មានដាក់អ្នកទោសច្រើនហួសចំណុះ ជាពិសេសគឺមជ្ឈមណ្ឌលកែប្រែទី១ (CC1) ពន្ធនាគារខេត្តបន្ទាយមានជ័យ ពន្ធនាគារក្រុងព្រះសីហនុ និងពន្ធនាគារខេត្តកំពង់ធំ (ជាពន្ធនាគារ ដែលទំហំអប្បបរិមានៃការរស់នៅរបស់អ្នកទោសគឺ១,៧ម² ក្នុងអ្នកទោសម្នាក់ តាមការកត់សំគាល់ក្នុង ឆ្នាំ១៩៩៨ ទំហំនេះបានថយចុះមកនៅត្រឹម 0,៩៧ម² ក្នុងអ្នកទោសម្នាក់ នៅក្នុងឆ្នាំ២០០១[៤]) ។ ពន្ធនាគារភាគច្រើនមានសភាពចាស់ទ្រុឌទ្រោមយ៉ាងខ្លាំង ។ ពន្ធនាគារភាគច្រើនមិនមានរបងរឹងមាំ ដើម្បីការពារបរិវេណពន្ធនាគារឡើយ ។ ការខ្វះខាតបន្ទប់ឃុំឃាំងនៅតែជាបញ្ហាបន្តមានរហូតមក ហើយជាទូទៅបន្ទប់ឃុំឃាំងមានសភាពតូចចង្អៀត ឬងងិតខ្លាំង ។ អ្នកទោសខ្លះត្រូវគេដាក់ឱ្យរស់នៅតាមទីធ្លា ឬដេកតាមច្រកផ្លូវដើរ ខណៈដែលអ្នកទោសដទៃទៀត មិនអាចចាកចេញពីបន្ទប់ ដែលមានអ្នកទោសច្រើនហួសចំណុះនោះបានទេ ។ អ្នកទោសគ្រប់រូបមានសិទ្ធិចេញមកក្រៅបន្ទប់ឃុំឃាំង ដើម្បីយកខ្យល់អាកាសយ៉ាងហោចណាស់ក៏១ ម៉ោងដែរក្នុងមួយថ្ងៃ[៥] ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវបានគេអនុវត្តទាល់តែសោះ ជាពិសេសនៅពន្ធនាគារប៉េហ្ស៊ីមជ្ឈមណ្ឌលកែប្រែទី១ ពន្ធនាគារខេត្តកណ្តាល និងពន្ធនាគារក្រុងព្រះសីហនុ[៦] ។

ការដាក់អ្នកទោសច្រើនហួសចំណុះ គឺជាការគំរាមកំហែងដល់សុខភាពអ្នកទោស នាំឱ្យមានការរាលដាលជំងឺឆ្លងកើនឡើង ដូចជា រមាស់ ស្លឹក និងការឆ្លងមេរោគផ្សេងៗ ដូចជាគ្រុនផ្តាសាយធំ (ដែលគេពិនិត្យឃើញមានរោគសញ្ញានេះ ១៤,១ % នៃអ្នកទោសសរុបក្នុងឆ្នាំ២០០១[៧] ។ បន្ទប់ទឹក និងកន្លែងដេករួមគ្នាធ្វើឱ្យអ្នកទោសប្រឈមមុខទៅនឹងបញ្ហាអនាម័យធ្ងន់ធ្ងរ ។ ការដាក់អ្នកទោសច្រើនហួសចំណុះ ជាធម្មតាគឺការបញ្ជូនអ្នកទោសពីតំបន់ដែលពួកគេរស់នៅ និងការបន្ថយការសួរសុខទុក្ខពីក្រុមគ្រួសារ ដែលនាំឱ្យមានការគំរាមកំហែងតទៅទៀត ដល់អ្នកទោសក្នុងការទទួលបានម្ហូបអាហារ ។ ករណីនេះតម្រូវឱ្យមានការដោះស្រាយជាបន្ទាន់ ចំពោះការដាក់អ្នកទោសច្រើនហួសចំណុះ ។

## មូលហេតុដែលបណ្តាលឱ្យមានការកើនឡើងនៃចំនួនអ្នកទោស

ពន្ធនាគារនៅតែជាទំរង់នៃការផ្តន្ទាទោសចំពោះបទល្មើសភាគច្រើន ទោះបីជាមានជំរើសផ្សេងៗជាច្រើនទៀត ដែលគេអាចយកមកប្រើប្រាស់បានក៏ដោយ ក៏ជំរើសទាំងនោះមិនទាន់បានដាក់បញ្ចូលទៅក្នុង

---

[៤] របាយការណ៍ស្តីពីស្ថានភាពពន្ធនាគារឆ្នាំ២០០១ ដោយអង្គការលីកាដូ ឆ្នាំ២០០២

[៥] ប្រកាសលេខ ២១៧ (ស្តីពីការគ្រប់គ្រងពន្ធនាគារ) មាត្រា ៧ ខ

[៦] ប្រកាសលេខ ២១៧ (ស្តីពីការគ្រប់គ្រងពន្ធនាគារ) មាត្រា ៧ ខ

[៧] សិទ្ធិមនុស្ស និងពន្ធនាគារកម្ពុជា: របាយការណ៍សុខភាពឆ្នាំ២០០១ របស់អង្គការលីកាដូ ឆ្នាំ២០០២

ច្បាប់កម្ពុជានៅឡើយទេ[៨] ។ គេបានប្រើប្រាស់ការផ្តន្ទាទោសក៏រិតអប្បរមា ដោយការផាកពិន័យ និងការព្យួរទោស ទោះបីជាមិនមានគោលការណ៏ណែនាំជាប្រព័ន្ធ សំរាប់ការអនុវត្តន៏របស់ខ្លួន ត្រូវបានរៀបចំឱ្យទៅជាច្បាប់ក៏ដោយ ។ មិនមានសេវាសហគមន៏ ដែលជាជំរើសសំរាប់ជនល្មើសជាអនិតិជន ដែលប្រព្រឹត្តបទល្មើសជាលើកដំបូងនោះទេ ទោះបីជាមន្ត្រីតុលាការភាគច្រើន និងរដ្ឋាភិបាលស្វាគមន៏ឱ្យមានគំរោងប្រភេទនេះ ដែលអាចជួយកាត់បន្ថយដល់ការចំណាយក៏ដោយ[៩] ។

**<u>ចំនួនអ្នកទោសក្នុងពន្ធនាគារកម្ពុជា ឆ្នាំ១៩៩៤ និង ឆ្នាំ២០០២</u>**

| ល.រ | ពន្ធនាគារ | ខែកញ្ញា ១៩៩៤[១០] | | ខែតុលា ២០០២[១១] | |
|---|---|---|---|---|---|
| | | ចំនួនអ្នកទោសសរុប | ចំនួនអ្នកទោសស្ត្រី | ចំនួនអ្នកទោសសរុប | ចំនួនអ្នកទោសស្ត្រី |
| ១ | T3 (បិទឆ្នាំ២000) | ២៣៧ | ២0 | - | - |
| ២ | CC1 (បើកឆ្នាំ២000) | - | - | ១២៨៤ | 0 |
| ៣ | CC2 (អតីត ព្រៃស) | ១៥៧ | 0 | ៣៤៧ | ១៩៨ |
| ៤ | CC3 (អតីត T5) | ២៥៥ | 0 | ៦២៤ | 0 |
| ៥ | P.J. | ៣៦ | ១0 | ៥៩ + | ៣ + |
| ៦ | បាត់ដំបង | ២១៣ | ១0 | ២៦៥ | 0 |
| ៧ | បន្ទាយមានជ័យ | ៩២ | ១ | ២៦៣ | ១៣ |
| ៨ | កំពង់ចាម | ១២៣ | ១៣ | ២៦៥ | 0 |
| ៩ | កំពង់ឆ្នាំង | ៥៧ | ២ | ១២៦ | ៤ |
| ១0 | កំពត | ៥៧ | ៨ | ១៧៦ | ១២ |
| ១១ | កំពង់ស្ពឺ | ៥៩ | 0 | ២0៥ | ២ |

[៨] បទដ្ឋានអប្បរមារបស់ អ.ស.ប ស្តីពីវិធានការនៃការដាក់ឱ្យនៅក្រៅឃុំ ដោយស្នើឱ្យដោះស្រាយករណីរឿងព្រហ្មទណ្ឌផ្សេងៗ តាមមធ្យោបាយនានាៗដូចជា ការដាក់ទណ្ឌកម្មដោយពាក្យសំដី ការបណ្តេញចេញដោយមានលក្ខខណ្ឌ ការពិន័យជាប្រាក់ ការរឹបអូសការជួសជុលសំណងការខូចខាត ការព្យួរទោស ការសាកល្បង បទបញ្ជាសេវាសហគមន៏ ការឃុំឃាំងក្នុងផ្ទះ ហើយនិងការបញ្ជូនទៅមជ្ឈមណ្ឌលប្រមូលផ្តុំជាដើម ។

[៩] ការសិក្សាអំពីលទ្ធភាព ក្នុងការបង្កើតឱ្យមានជំរើសនៃការដាក់ឱ្យនៅក្រៅឃុំជាផ្លូវការ ទៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ឆ្នាំ១៩៩៧ ។

[១០] តួលេខរបស់នាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ

[១១] តួលេខរបស់កម្មវិធីជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា (CCJAP) ។

| | | | | | |
|---|---|---|---|---|---|
| ១២ | កំពង់ធំ | ៤៩ | ១ | ៩៨ | ៣ |
| ១៣ | កណ្ដាល | ៩៦ | ៦ | ២៥៣ | ១៧ |
| ១៤ | កោះកុង | ៤៦* | ៣* | ៧៩ | ២ |
| ១៥ | ក្រចេះ | ២៣ | ១ | ១២៥ | ៧ |
| ១៦ | មណ្ឌលគីរី | ១៥* | ១* | ៩៨ | ១ |
| ១៧ | ព្រះវិហារ | ៥ | ០ | ៦៥ | ០ |
| ១៨ | ព្រៃវែង | ៧២ | ១ | ១៤៩ | ១០ |
| ១៩ | ពោធិសាត់ | ៤៤ | ២ | ៩៥ | ១ |
| ២០ | រតនគីរី | ១៩ | ០ | ៩៨ | ១ |
| ២១ | សៀមរាប | ៩៧ | ៣ | ៥៦៦ | ១៧ |
| ២២ | ក្រុងព្រះសីហនុ | ៦០ | ៣ | ១៤០ | ១៤ |
| ២៣ | ស្ទឹងត្រែង | ២៦* | ២* | ៩៨ | ៥ |
| ២៤ | ស្វាយរៀង | ៦៨ | ២ | ១៤៣ | ៨ |
| ២៥ | តាកែវ | ៧៥ | ៥ | ១៣៩ | ១០ |
| **សារុប** | | **១៩៨១** | **៩៣** | **៥៧៦០** | **៣២៨** |

* ចំនួនអ្នកទោសរាយការណ៍ មកត្រឹមខែមិថុនា ឆ្នាំ១៩៩៤ + ចំនួនអ្នកទោសរាយការណ៍មកត្រឹមខែមិថុនា ឆ្នាំ២០០២

ប្រមាណជា ៣០% នៃអ្នកទោសទាំងអស់ មិនទាន់ត្រូវបានតុលាការផ្តន្ទាទោសពីបទល្មើសណាមួយនៅឡើយទេ ពួកគេកំពុងស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ។ នេះគឺជាផលវិបាកមួយផ្នែកនៃកិច្ចដំណើរការក្តីរបស់តុលាការ ដែលមានការយឺតយ៉ាវ ហើយមួយផ្នែកទៀតគឺតុលាការកម្ពុជា មានទំនោរទៅរកការបញ្ជូនអ្នកទោសត្រឡប់ទៅកន្លែងឃុំឃាំង ដែលនេះគឺជាការអនុវត្តន៍ទូទៅទៅហើយ ។ ការអនុវត្តន៍បែបនេះ គឺផ្ទុយទៅនឹងបទដ្ឋានអន្តរជាតិ និងច្បាប់ព្រហ្មទណ្ឌកម្ពុជាបច្ចុប្បន្ន ដែលចែងយ៉ាងច្បាស់អំពីលក្ខណៈវិនិច្ឆ័យ សំរាប់អនុវត្តចំពោះការឃុំខ្លួនបណ្តោះអាសន្នគឺ :

*"មានតែចៅក្រមទេ ដែលអាចសម្រេចដោយមានចែងមូលហេតុ ឱ្យឃុំខ្លួនជនជាប់ចោទក្នុងមន្ទីរឃុំឃាំងតាមសេចក្តីស្នើសុំរបស់រដ្ឋអាជ្ញា ហើយមានតែក្នុងករណីដែលបារម្ភខ្លាចក្រែងជននោះរត់គេចខ្លួននិងដោយគ្មានអ្វីអាចឱ្យធានាបានថា ជនជាប់ចោទប្រាកដជាត្រឡប់មកបង្ហាញខ្លួនចំពោះមុខតុលាការវិញ មានន័យថាសាមីជនគ្មានការងារធ្វើ គ្មានគ្រួសារ គ្មានទីលំនៅពិតប្រាកដ ឬដោយខ្លាចជនជាប់ចោទនោះប្រើឥទ្ធិពលលើសាក្សី ឬលើដំណើរការស៊ើបអង្កេត ។"*

មាត្រា១៤.១ នៃច្បាប់អ៊ុនតាក់

ទោះជាមានបញ្ញត្តិនេះក៏ដោយ ក៏ការអនុវត្តនីជាក់ស្តែងគេនៅតែធ្វើមិនដឹងមិនឮជាដដែល សូម្បីតែជនដែល ត្រូវបានគេចោទប្រកាន់ពីបទល្មើសតូចតាចក៏ត្រូវបានគេដាក់ពន្ធនាគាររយៈពេលដ៏យូររង់ចាំសវនាការដែរ ។

## ២. សុខភាព

ការដាក់អ្នកទោសហួសចំណុះជារៀងរហូតមក នៅក្នុងពន្ធនាគារកម្ពុជា គឺជាការរួមចំណែកដ៏ធំមួយ ក្នុងការធ្វើឱ្យខូចសុខភាពអ្នកទោស ។ ទោះជាដូច្នេះក្តី សុខភាពក៏ត្រូវទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរផងដែរ ដោយសារម្ហូបអាហារមិនគ្រប់គ្រាន់ និងទឹកស្អាត ដែលបញ្ហាទាំងនេះមានការប្រែប្រួលតិចតួច នៅក្នុងរយៈពេល ៨ ឆ្នាំ ចុងក្រោយនេះ ។

### ម្ហូបអាហារ និង ទឹក

*របាយការណ៍ស្តីអំពីស្ថានភាពពន្ធនាគារនៃប្រទេសកម្ពុជា* បានរកឃើញថា នៅក្នុងឆ្នាំ១៩៩៤ មានអ្នកទោសភាគច្រើនស្ថិតក្នុង "ភាពអត់ឃ្លានជានិច្ច" ។ ក្នុងចំណោមអ្នកទោស ដែលបានស្ទង់មតិ មានអ្នកទោស ៧៨% បានត្អូញត្អែរថា ពួកគេមិនមានអាហារហូបចុកគ្រប់គ្រាន់ទេ ហើយអ្នកទោសច្រើនជាង ៦០% បានអះអាងថា ការខ្វះអាហារហូបចុកគឺជាបញ្ហាធំបំផុតតែមួយគត់ ដែលពួកគេជួបប្រទះ ។ ស្ថានការណ៍នេះ មិនមានការផ្លាស់ប្តូរទេ ។ ថវិកាប្រចាំថ្ងៃសំរាប់អ្នកទោសម្នាក់ៗ នៅតែ១០០០រៀលជាដដែល ហើយថវិកានេះត្រូវប្រើប្រាស់ផងដែរ សំរាប់ទិញអុសដុត និងសម្ភារៈសំរាប់ដាំស្ល ។ ការសិក្សាស្រាវជ្រាវបានបង្ហាញថា អ្នកទោសខ្លះទទួលបានអាហារដែលមានជាតិកាឡូរីតិចតួចបំផុតគឺប្រមាណជា ១២០០កាឡូរី ក្នុងមួយថ្ងៃ បើប្រៀបធៀបទៅនឹងកំរិតអាហារប្រចាំថ្ងៃជាអប្បរមាសំរាប់មនុស្សប្រុសពេញវ័យគឺ ២២០០កាឡូរី ។

ពន្ធនាគារមួយចំនួនជួបប្រទះការខ្វះខាតទឹកជាខ្លាំង រួមទាំងពន្ធនាគារខេត្តបន្ទាយមានជ័យ ព្រះវិហារ និងក្រុងព្រះសីហនុ ។ គំរោងថ្មីមួយរបស់សមាគមពន្ធនាគារ (Prison Fellowship) បាន បង្កើតឧបករណ៍ចម្រោះទឹកដោយខ្សាច់ សំរាប់ដាក់គ្រប់បន្ទប់ពន្ធនាគារ CC1 និង CC2 ទោះបីជាដូច្នោះក្តី ក៏គេនៅតែត្រូវមើលថាតើមានទឹកគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់តាមធុងចម្រោះទឹកទាំងនោះនៅរដូវប្រាំងដែរឬទេ ។ បណ្តាញលូទឹកសំអុយគ្រប់ពន្ធនាគារកម្ពុជា ទាមទារឱ្យមានការរៀបចំឡើងវិញ ដើម្បីជៀសវាងការធ្វើឱ្យក្រខ្វក់ដល់ប្រភពទឹកសំរាប់អ្នកទោសប្រើប្រាស់ ហើយត្រូវមានថវិការសំរាប់បង់ថ្លៃទឹក ដែលប្រើប្រាស់នៅក្នុងពន្ធនាគារ ។

## សេវាពេទ្យ

*របាយការណ៍ស្តីពីស្ថានភាពពន្ធនាគារនៃប្រទេសកម្ពុជា* បានសំគាល់ឃើញថា ក្នុងខែកញ្ញា ឆ្នាំ១៩៩៤ ក្រសួងសុខាភិបាល "ត្រូវបានគេរាយការណ៍ថា ជាអ្នកទទួលខុសត្រូវក្នុងការផ្តល់សេវាពេទ្យដល់ពន្ធនាគារទាំងអស់។ ទោះជាដូច្នេះក្តី នៅក្នុងពេលធ្វើទស្សនកិច្ចតាមពន្ធនាគារនានា គេមិនឃើញមានភស្តុតាងណាមួយបង្ហាញថាមានសេវាកម្មនោះឡើយ"។ របាយការណ៍នោះ បានលើកឡើងផងដែរ អំពីសភាពទ្រុឌទ្រោមនៃតួអាគារពន្ធនាគារ ការខ្វះអនាម័យ និងការផ្តល់កម្មករបោសសំអាតមិនបានគ្រប់គ្រាន់ ជាកត្តារួមចំណែកដល់ការធ្វើឱ្យ " សុខភាពអ្នកទោសចុះខ្សោយខ្លាំង " ដោយសំគាល់ឃើញថា មានអ្នកទោសជាច្រើននាក់ " នឹងត្រូវស្លាប់ដោយសារតែការធ្វេសប្រហែសទាំងនេះ" ។

ចរិតនិងទំហំនៃបញ្ហាសុខភាព ដែលអ្នកទោសបានពោលអះអាង នៅក្នុងឆ្នាំ១៩៩៤ គឺមានសភាពដូចគ្នាស្ទើរតែទាំងស្រុងនឹងពេលបច្ចុប្បន្ននេះ។ នៅដើមឆ្នាំ២000 នាយកដ្ឋានសុខភាពពន្ធនាគារ ក្រសួងមហាផ្ទៃ ត្រូវបានបង្កើតឡើង ។ នាយកដ្ឋាននេះ បានទទួលថវិការជាច្រើន តាមរយៈទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់អូស្ត្រាលី "AUSAID"។ ទោះជាដូច្នោះក្តី ក្រៅពីការធ្វើពង្រាងសៀវភៅណែនាំស្តីពីសុខភាពពន្ធនាគារ និងផែនការស្តីពីសហប្រតិបត្តិការរវាងក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាលចេញ គឺមានការងារតិចតួចណាស់ដែលបានធ្វើ ដើម្បីបង្កើនកិច្ចគាំពារសុខភាពអ្នកទោស។ អ្នកទោសភាគច្រើនលើសលុបពឹងផ្អែកលើជំនួយរបស់អង្គការក្រៅរដ្ឋាភិបាលនានា។

នៅមិនទាន់មានគោលការណ៍ណែនាំច្បាស់លាស់នៅឡើយ អំពីកិច្ចសហប្រតិបត្តិការរវាងក្រសួងទាំងពីរទាក់ទងនឹងការផ្តល់កិច្ចគាំពារសុខភាពដល់អ្នកទោស។ បុគ្គលិកពេទ្យដែលបញ្ជូនឱ្យទៅធ្វើការនៅពន្ធនាគារជារឿយៗជាអ្នកដែលមិនបានទទួលការបណ្តុះបណ្តាលជំនាញត្រឹមត្រូវ ហើយខ្វះធនធានចាំបាច់ផ្សេងៗ ដូចជាឧបករណ៍មូលដ្ឋានសំរាប់ពេទ្យ ថ្នាំពេទ្យ និងមធ្យោបាយធ្វើដំណើរ។ អ្នកទោសមិនបានទទួលការពិនិត្យសុខភាពជាធម្មតា នៅពេលបញ្ជូនចូលទៅក្នុងពន្ធនាគារ ហើយកំណត់ហេតុពេទ្យទៀតសោធ ក៏មិនបានរក្សាទុកឱ្យបានគត់មត់ដែរ។

សំភារៈសំរាប់អនាម័យ និងបង្ការជម្ងឺ នៅតែមានការខ្វះខាតខ្លាំងជាដដែល។ អ្នកទោសមានសិទ្ធិទទួលបានសម្ភារៈប្រើប្រាស់ជាទៀងទាត់ដូចជា កន្ទេល មុង សាប៊ូ ។ល។ ទោះជាដូច្នេះក្តី សម្ភារៈប្រើប្រាស់មានកំរិតដែលធ្លាប់បានផ្តល់ឱ្យអ្នកទោសកាលពី ៨ ឆ្នាំកន្លងមក បច្ចុប្បន្ននេះ ត្រូវបានកាត់បន្ថយមកនៅត្រឹម

ក៏រិតតិចតួច គឺផ្តល់ឱ្យតែសំលៀកបំពាក់ឯកសណ្ឋានពន្ធនាគារតែប៉ុណ្ណោះ ។ គ្រួសារអ្នកទោស និងអង្គការក្រៅរដ្ឋាភិបាលនានា គឺជាប្រភពដ៏សំខាន់នៃសេចក្តីត្រូវការជាមូលដ្ឋាន ដូចជាសាប៊ូ ជាដើម បើគ្មានវាទេនឹងបណ្តាលឱ្យមានជម្ងឺសើរស្បែកដូចជា រមាស់ ជាដើម ។ គេមិនបានដឹងច្បាប់អំពីមូលហេតុនៃការខកខានក្នុងការផ្គត់ផ្គង់សម្ភារៈជាមូលដ្ឋានទាំងនេះឡើយ ក៏ប៉ុន្តែប្រធានពន្ធនាគារ ត្រូវធ្វើដំណើរជាទៀងទាត់មករាជធានីភ្នំពេញ ដើម្បីបើកប្រាក់សំរាប់ម្ហូបអាហារ និងសម្ភារៈផ្សេងៗ ហើយថ្លៃចំណាយក្នុងការធ្វើដំណើរត្រូវបានកាត់ចេញពីថវិការនេះ ។ នាយកដ្ឋានមួយចំនួនរបស់រដ្ឋាភិបាល ត្រូវបានគេចោទប្រកាន់ថាបានកាត់យកប្រាក់ជាច្រើនពីខ្ទង់ថវិការទាំងនេះ ដើម្បីធានាដល់ការបើកប្រាក់ឱ្យបានរហ័សទាន់ពេលវេលា ។

អ្នកទោសស្លាប់នៅក្នុងពន្ធនាគារ នឹងត្រូវគេស៊ើបអង្កេត ប្រសិនបើមានហេតុផលដែលគេសង្ស័យថាមិនជាប់ពាក់ព័ន្ធទៅនឹងការព្យាបាលពេទ្យ កាលបើច្បាប់ ឬបទដ្ឋានអន្តរជាតិតម្រូវថា អ្នកទោសដែលត្រូវព្យាបាលដោយគ្រូពេទ្យឯកទេស ត្រូវបានបញ្ជូនទៅស្ថាប័នឯកទេស ឬមន្ទីរពេទ្យ[១២] ការនេះបានប្រព្រឹត្តធ្វើទៅជាដដែលៗដោយមានភាពយឺតយ៉ាវបំផុត នៅក្នុងប្រទេសកម្ពុជា[១៣] ។ ជាធម្មតា គេបញ្ជូនអ្នកទោសទៅមន្ទីរពេទ្យ លុះត្រាតែគេឃើញច្បាស់ថា អ្នកទោសនោះជិតស្លាប់ហើយ បើទោះបីជាមុនពេលបញ្ជូន និងការយកចិត្តទុកដាក់ព្យាបាលត្រឹមត្រូវ អាចជួយសង្គ្រោះជីវិតពួកគេក៏ដោយ ។ ការខ្វះខាតថវិកាសំរាប់ដឹកជញ្ជូន និងការខ្វះអ្នកយាម គឺជាហេតុផលដែលគេបានលើកឡើងជាញឹកញាប់ ។ យ៉ាងហោចណាស់ មានអ្នកទោស ៤៨ នាក់ ស្លាប់ដោយជំងឺក្នុងឆ្នាំ ២00១ ។

ក្នុងចំណោមអ្នកទោស ៣0 នាក់ ដែលបានស្លាប់ ក្នុងឆ្នាំ២00១ មានឈ្មោះក្នុងបញ្ជីឃុំឃាំងនៅក្នុងពន្ធនាគារ CC1 អ្នកទោសប្រមាណជា ២៥ នាក់ ត្រូវបានគេបញ្ជូនទៅកាន់មន្ទីរពេទ្យនគរបាលមុនីវង្ស មិនយូរប៉ុន្មាននៅមុនពេលស្លាប់ ។ បន្ទប់សំរាប់ព្យាបាលអ្នកទោស នៅមន្ទីរពេទ្យនេះមានសភាពក្តៅខ្លាំង និងគ្មានអនាម័យទាល់តែសោះ ។ ផែនការផ្ទេរមន្ទីរពេទ្យនេះ ទៅមន្ទីរពេទ្យមួយទៀត នៅក្នុងឆ្នាំ២00២ នៅមិនទាន់ដឹងប្រាកដនៅឡើយ ។

---

[១២] បទដ្ឋានអប្បរមានៃ អ.ស.ប សំរាប់គ្រប់គ្រងអ្នកទោស ចំណុច ២២

[១៣] បទដ្ឋានអប្បរមានៃ អ.ស.ប សំរាប់គ្រប់គ្រងអ្នកទោស ចំណុច ២២

មិនមានការយកចិត្តទុកដាក់ជាពិសេស ចំពោះអ្នកទោសដែលមានជំងឺអេដស៍ (HIV/AIDS) ដែលជាប្រភេទជំងឺមួយគ្រោះថ្នាក់បំផុត ។ ក្នុងឆ្នាំ២០០១ មានអ្នកទោសប្រមាណជា ២០ នាក់ ត្រូវបានគេរាយការណ៍ថាបានស្លាប់ដោយមានការបញ្ជាក់ច្បាស់ ឬសង្ស័យថា ដោយសារជំងឺអេដស៍ ។ គេមិនទាន់ឃើញមានគោលនយោបាយសមស្របណាមួយ សំរាប់អ្នកទោសដែលមានជំងឺអេដស៍ទេ ហើយកម្រឃើញមានការលើកលែងទោស ចំពោះអ្នកទោសដែលស្ថិតក្នុងដំណាក់កាលចុងក្រោយនៃជំងឺអេដស៍ណាស់ ។ អ្នកទោសភាគច្រើនដែលផ្ទុកមេរោគអេដស៍ ក៏មានកើតជំងឺឱកាសនិយម ដូចជាជំងឺរបេង ដែលជាជំងឺឆ្លងខ្លាំងបំផុត ដែលងាយឆ្លងទៅអ្នកទោសដទៃទៀតនៅក្នុងពន្ធនាគារ ។

## ៣. ការគ្រប់គ្រងពន្ធនាគារ

*របាយការណ៍ស្តីអំពីស្ថានភាពពន្ធនាគារនៃប្រទេសកម្ពុជា* បានបរិយាយអំពីការគ្រប់គ្រងពន្ធនាគារកម្ពុជាថាជា "របៀបគ្រប់គ្រងហួសសម័យ ដែលបង្កើតភាពស្មុគស្មាញដោយខ្លួនឯង...ជាប្រព័ន្ធមួយដែលនាំមកនូវបញ្ហាជាច្រើនមិនអាចជៀសផុត ដូចជាទំនាក់ទំនងមិនល្អជាទូទៅ និងផ្គត់ផ្គង់ដល់ពន្ធនាគារ សីលធម៌របស់មន្ត្រីពន្ធនាគារនៅមានកំរិតទាប ព្រមទាំងមិនបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់" ។

ផ្នែកមួយចំនួននៃការគ្រប់គ្រងពន្ធនាគារមានការរីកចំរើន ។ មានការបែងចែកដាច់ពីគ្នារវាងសេវាពន្ធនាគារ និងនគរបាល ដែលក្នុងនោះ ប្រធានពន្ធនាគារមិនធ្វើរបាយការណ៍ទៅស្នងការរងនគរបាលមូលដ្ឋានទៀតទេ ។ ការិយាល័យកិច្ចការតុលាការ និងពន្ធនាគារខេត្ត/ក្រុង បច្ចុប្បន្ននេះ ស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីអភិបាលរងទី២ ខេត្ត/ក្រុង ។ ក្រៅពីនេះ មានការផ្តួចផ្តើមគំនិត ដើម្បីបង្កើនសមត្ថភាពដល់មន្ត្រីពន្ធនាគារ រួមទាំងតាមរយៈកម្មវិធីទ្រទ្រង់តុលាការ (JMP) របស់ការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា និងតាមរយៈកម្មវិធីជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា (CCJAP) ។

ទោះជាដូច្នោះក្តី ក៏នៅមានបញ្ហាធ្ងន់ធ្ងរបន្តមាននៅក្នុងវិស័យជាច្រើន រួមមាននីតិវិធីហិរញ្ញវត្ថុ ដែលមានផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាព និងសុខមាលភាពអ្នកទោស បញ្ហាទំនាក់ទំនងមានការយឺតយ៉ាវ និងធ្វើឱ្យការគ្រប់គ្រងពន្ធនាគារមានភាពស្មុគស្មាញ បញ្ហាប្រាក់បៀវត្សរ៍ទាប លក្ខខណ្ឌការងារ និងសមត្ថភាពរបស់មន្ត្រីពន្ធនាគារ នៅតែបន្តមានជាបញ្ហាដដែល ។

**មធ្យោបាយដឹកជញ្ជូន**

បញ្ហាធំមួយ ក្នុងចំណោមបញ្ហាធំៗដទៃទៀត ដែលសេវាពន្ធនាគារកម្ពុជាកំពុងជួបប្រទះ គឺការខ្វះមធ្យោបាយដឹកជញ្ជូនអ្នកទោស។

ជារឿយៗ តុលាការលើកពេលសវនាការ ក៏ព្រោះតែអ្នកទោសមិនអាចមកចូលរួមបាន។ បញ្ហានេះបង្កើនបន្ទុកដល់ការឃុំខ្លួនបណ្តោះអាសន្ន និងនាំឱ្យមានចំនួនអ្នកទោសច្រើនហួសចំណុះក្នុងបន្ទប់ឃុំឃាំង។ ក្នុងករណីផ្សេងទៀត តុលាការបើក*សវនាការកំបាំងមុខ* ដែលនេះគឺជាការរំលោភលើសិទ្ធិជនជាប់ចោទក្នុងការមានវត្តមានក្នុងសវនាការរបស់ខ្លួន។ រីឯអ្នកទោសដែលជាសាក្សីក្នុងករណីផ្សេងទៀត ក៏កម្រឃើញមានវត្តមានដើម្បីផ្តល់ចំលើយ និងដើម្បីឱ្យតុលាការសួរដេញដោលផងដែរ។

បញ្ហានេះមានសភាពធ្ងន់ធ្ងរជាពិសេស នៅពេលដែលត្រូវបញ្ជូនអ្នកទោសទៅចូលរួមក្នុងសវនាការនៅសាលាឧទ្ធរណ៍ និងតុលាការកំពូល ។ តុលាការទាំងនេះ តាំងនៅរាជធានីភ្នំពេញ ដូច្នោះហើយគេត្រូវធ្វើដំណើរផ្លូវឆ្ងាយ និងត្រូវចំណាយថ្លៃធ្វើដំណើរខ្ពស់ ចំពោះអ្នកទោសនៅតាមបណ្តាខេត្តនានា។ អ្នកទោសខ្លះត្រូវចំណាយពេលច្រើនឆ្នាំ រង់ចាំសវនាការនៅសាលាឧទ្ធរណ៍ ហើយរយៈពេលនេះមិនត្រូវបានគេទូទាត់សងវិញទេ ប្រសិនបើពួកគេត្រូវបានលើកលែងចោទប្រកាន់ជាយកថាហេតុ។ ការព្រួយបារម្ភនៅតែមាន អំពីអ្នកទោសដែលរង់ចាំសវនាការនៅសាលាឧទ្ធរណ៍ ហើយដែលបានបំពេញរយៈពេលទោស ដែលតុលាការខេត្ត/ក្រុងបានសំរេចរួចហើយ គឺនៅតែបន្តជាប់ពន្ធនាគាររហូតទាល់តែសាលាឧទ្ធរណ៍បើកសវនាការ ឬ លើកលែងការចោទប្រកាន់។ គេអាចធ្វើឱ្យមានការរីកចំរើនជាដំកំភួន និងឈានទៅរកការលុបបំបាត់បញ្ហាទាំងនេះបាន ដោយបង្កើតឱ្យមានសាលាឧទ្ធរណ៍ថ្នាក់តំបន់ ឬសាលាឧទ្ធរណ៍ចល័ត។

ជារឿយៗ មូលហេតុចំបងនៃការខ្វះមធ្យោបាយដឹកជញ្ជូន គឺបញ្ហាថវិកាសំរាប់ចំណាយលើប្រេងឥន្ធនៈ ហើយជួនកាលថ្លៃជួលរថយន្ត និងប្រាក់បន្ថែមលើប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ សំរាប់បុគ្គលិកពន្ធនាគារ ក្នុងការយាមកាមនៅពេលដឹកជញ្ជូនអ្នកទោស ក៏ដូចជាការពិនិត្យតុលាការនានា ប្រព័ន្ធដឹកជញ្ជូនអ្នកទោសនៅទូទាំងប្រទេសកម្ពុជាត្រូវតែបង្កើតឡើង និងចាត់ទុកជាការប្រញាប់។

ស្ថានភាពដឹកជញ្ជូន ក៏អាចមានផលប៉ះពាល់ជាចំបងផងដែរ ដល់សុខភាពរបស់អ្នកទោស ដូចបាន កត់សំគាល់ខាងលើ អ្នកទោសដែលមានជំងឺធ្ងន់ គេកម្រនឹងបញ្ជូនទៅមន្ទីរពេទ្យណាស់ លុះត្រាតែអ្នកជំងឺនោះ ជិតស្លាប់ទើបគេបញ្ជូន។

## ៤. ការគំរាមកំហែងដល់សុវត្ថិភាពអ្នកទោស

### ការមិនបានបំបែកអ្នកទោសតាម អាយុ ភេទ និង បទល្មើស

បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់ការគ្រប់គ្រងអ្នកទោសចែងថា " ចំពោះមន្ទីរឃុំឃាំងដែលទទួល យកទាំងអ្នកទោសប្រុស និងអ្នកទោសស្រីនោះ បរិវេណសំរាប់ដាក់អ្នកទោសស្រីត្រូវតែនៅដាច់ដោយឡែកពីគ្នា ជាដាច់ខាត ហើយអ្នកទោសក្មេងៗ "យុវទោសករ "ត្រូវដាក់ឱ្យនៅដាច់ដោយឡែកពីអ្នកទោសពេញវ័យ"[១៤] ។ ដូច ជានៅក្នុងឆ្នាំ១៩៩៤ បទបញ្ញត្តិទាំងនេះ កម្រមានគេអនុវត្តតាមណាស់នៅពន្ធនាគារនានា ក្រៅរាជធានីភ្នំពេញ។ ទោះបីជាតាមធម្មតា អ្នកទោសប្រុស និងអ្នកទោសស្រី មានបន្ទប់ឃុំឃាំងផ្សេងគ្នាក្តី ក៏នៅពេលចេញមកខាង ក្រៅបន្ទប់ ពួកគេអាចនៅលាយឡំគ្នាដោយសេរី ហើយអ្នកទោសក្មេងៗ "យុវទោសករ " ជារឿយៗ ត្រូវបានគេ ដាក់ឱ្យនៅជាមួយអ្នកទោសពេញវ័យ[១៥] ។ មានការខិតខំតិចតួចឬគ្មានទាល់តែសោះ ដើម្បីបំបែកចេញពីគ្នារវាង អ្នកប្រព្រឹត្តបទល្មើសតូចតាច និងអ្នកប្រព្រឹត្តបទឧក្រិដ្ឋ ឬអ្នកជាប់ឃុំឃាំងបណ្តោះអាសន្នរងចាំសវនាការពិទណ្ឌិត ដែលនេះជាការប្រែក្លាយពន្ធនាគារកម្ពុជាទៅជាសាលាឧក្រិដ្ឋកម្មមួយដ៏មានប្រសិទ្ធភាពសំរាប់ក្មេងៗ និងអ្នកដែល ងាយទទួលរងគ្រោះ។ នៅពេលជាមួយគ្នានេះដែរ មានផលវិបាកជាទូទៅ ដោយសារគ្មានអាគារគ្រប់គ្រាន់សំរាប់ ដាក់អ្នកទោស ការដាក់អ្នកទោសឱ្យនៅលាយលំគ្នា ក៏អាចបង្កើតឱ្យមានអំពើរំលោភធ្ងន់ធ្ងរ ជាពិសេសការរំលោភ បំពានខាងផ្លូវភេទលើស្ត្រី។

### ការមិនបានផ្តន្ទាទោស ចំពោះការធ្វើទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ និងដែលនាំឱ្យ បាត់បង់តំលៃជាមនុស្ស

ករណីភាគច្រើនដែលបានរាយការណ៍ ទាក់ទងនឹងការធ្វើទារុណកម្ម និងការដាក់ទណ្ឌកម្ម ក្នុងរូបភាព ឃោរឃៅ អមនុស្សធម៌ និងនាំឱ្យបាត់បង់តំលៃជាមនុស្ស កើតមាននៅកន្លែងឃុំឃាំងរបស់នគរបាល ប៉ុន្តែឧប្បត្តិ ហេតុនេះ ក៏កើតមានផងដែរ នៅក្នុងពន្ធនាគារនានា។ បើតាមការស្ទង់មតិធ្វើឡើងសំរាប់របាយការណ៍ស្តីពី *ស្ថានភាពពន្ធនាគារនៅប្រទេសកម្ពុជា* មានជនជាប់ចោទ ៤៦% បានអះអាងថា ខ្លួនបានទទួលរងដោយការធ្វើ

---

[១៤] បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់ការគ្រប់គ្រងអ្នកទោស ចំណុច ៨

[១៥] បញ្ហាកង្វល់ជាទូទៅមួយចំនួននៅក្នុងពន្ធនាគារ, ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ឆ្នាំ២០០១

ទារុណកម្ម ៦៥% ដោយការវាយដំ ៥២% ដោយការឃុំឃាំងឱ្យនៅឯកោដាច់ពីគេ ហើយ ២៥% ទៀតដោយការបញ្ជាឱ្យធ្វើពលកម្មហួសកំណត់ ទុកជាការដាក់ទណ្ឌកម្មខាងវិន័យ ។

របាយការណ៍ជាច្រើនបានបង្ហាញថា ការធ្វើទារុណកម្មនៅក្នុងពន្ធនាគារអាចមានការថយចុះ ចាប់ពីឆ្នាំ១៩៩៤មក ដែលនេះជានិន្នាការមួយគួរឱ្យស្វាគមន៍ ។ ទោះបីជាដូច្នេះក្តី ក៏គេកត់សំគាល់ឃើញហេតុការណ៍ទាំងនេះ នៅតែបន្តកើតមានជាដដែល ហើយការព្រួយបារម្ភបំផុតនោះគឺ មិនមានជនណាម្នាក់ត្រូវបានផ្តន្ទាទោសចំពោះបទល្មើសនេះឡើយ ចាប់ពីពេលដែលការិយាល័យសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បានចាប់ផ្តើមការងារឃ្លាំមើលពន្ធនាគារកម្ពុជា[១៦] ។ ករណីនៃការផ្តន្ទាទោសកើតមានជាលើកដំបូង ក្នុងខែសីហា ឆ្នាំ២០០២ នៅពេលដែលឆ្មាំពន្ធនាគារចំនួន ៥ នាក់ ត្រូវបានគេចោទប្រកាន់ថាបានធ្វើការវាយដំអ្នកទោសយ៉ាងធ្ងន់ធ្ងរ ក្រោយពេលដែលអ្នកទោសបានព្យាយាមរត់គេចេញពីពន្ធនាគារ ។ ទោះបីជាមានភស្តុតាងជាក់ច្បាស់ អំពីកំហុសរបស់ពួកគេក្តី ក៏ឆ្មាំពន្ធនាគារទាំងនោះ ត្រូវបានតុលាការលើកលែងការចោទប្រកាន់ដែរ ។ (សូមមើល ផ្នែកខាងក្រោម) ។

ការធ្វើទារុណកម្ម ឃោរឃៅ អមនុស្សធម៌ និងនាំឱ្យខូចតំលៃជាមនុស្សនៅក្នុងពន្ធនគារបច្ចុប្បន្ននេះ ទំនងជាមានជាប់ពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងបទល្មើសខាងវិន័យ ហើយជាពិសេស គឺការប៉ុនប៉ងរត់គេចចេញពីពន្ធនាគារ ។ មានការដាក់ទណ្ឌកម្មតាមទំនើងចិត្ត រួមមានការវាយដំយ៉ាងធ្ងន់ធ្ងរ ការដាក់កំហិតលើម្ហូប អាហារ និង ទឹក ការដាក់ខ្នោះ និងការប្រើប្រាស់បន្ទប់តូច និងទ្រុងដ៏ចង្អៀតដាច់ពីគេ ។

## ការប្រើប្រាស់វិធីបង្ខាំងលើរូបកាយដោយខុសច្បាប់

តាមការស្ទង់មតិ ដែលបានធ្វើឡើងសំរាប់*របាយការណ៍ស្តីពីស្ថានភាពពន្ធនាគារនៅប្រទេសកម្ពុជា* មានជនជាប់ចោទ ៤០% បានរាយការណ៍ពីការប្រើវិធីបង្ខាំងលើរូបកាយ មានដូចជាការដាក់ខ្នោះ ជាការដាក់ទណ្ឌកម្ម ។ ការប្រើប្រាស់វិធីដាក់ខ្នោះ គឺជាការរំលោភទៅលើបញ្ញត្តិជាបទដ្ឋានអប្បរមាសំរាប់ការគ្រប់គ្រងអ្នកទោស ហើយនិងច្បាប់អ៊ុនតាក់មាត្រា១២ ។ ការប្រើប្រាស់វិធីបង្ខាំងលើរូបកាយ ក្រៅពីការដាក់ខ្នោះដៃ ដែលអនុញ្ញាតសំរាប់តែការដឹកជញ្ជូនអ្នកទោសនោះ គឺមិនអាចទទួលយកបានជាដាច់ខាត ។ នៅខណៈដែលបញ្ហានេះហាក់មានការថយចុះ ពន្ធនាគារខ្លះនៅមិនព្រមលះបង់ការប្រើខ្នោះដៃ ខ្នោះជើង និងវិធីបង្ខាំងលើ

---

[១៦] នៅមុនខែសីហា ឆ្នាំ២០០២ ការផ្តន្ទាទោស ដែលគេបានដឹងជាចុងក្រោយ ទៅលើមន្ត្រីពន្ធនាគារ ពីបទប្រើអំពើទារុណកម្ម គឺនៅក្នុងឆ្នាំ១៩៩៣ កាលនោះអនុប្រធានពន្ធនាគារខេត្តបាត់ដំបង (ត្រូវបានប៉ូលីសអ៊ុនតាក់ចាប់ខ្លួន) ហើយបានផ្តន្ទាទោសពីបទប្រើអំពើហឹង្សា រួមមានការចងអ្នកទោសជាប់ទៅនឹងដើមឈើ ហើយយកដែកក្តៅដុតពួកគេ ។ មន្ត្រីពន្ធនាគាររូបនោះ ត្រូវបានផ្តន្ទាទោសដាក់គុករយៈពេលមួយឆ្នាំ ទោះបីជាគេមិនបានដឹងថា ទោសគុកនោះត្រូវបានគេអនុវត្តដែរឬទេ ។

រូបកាយផ្សេងទៀត ដែលមិនចាំបាច់ ជាវិធានការដាក់វិន័យ ឬគ្រាន់តែជាការជំនួសឱ្យវិធានការពង្រឹងសន្តិសុខធម្មតាប៉ុណ្ណោះ ។ ជាឧទាហរណ៍ នាពេលថ្មីៗនេះ មានករណីអ្នកទោស ៥ នាក់ ត្រូវបានគេដាក់ខ្នោះជើងនៅក្នុងពន្ធនាគារ CC3 ក្នុងពាក់កណ្តាលឆ្នាំ២០០២ ជាទណ្ឌកម្មសំរាប់ការប៉ុនប៉ងគេចខ្លួនចេញពីពន្ធនាគារ ។

## អំពើហឹង្សាក្នុងចំណោមអ្នកទោស

របាយការណ៍ស្តីអំពី*ស្ថានភាពពន្ធនាគារនៅប្រទេសកម្ពុជា* បានរកឃើញថាមានអ្នកទោស៦០% បានអះអាងថា មិនមានការប្រើអំពើហិង្សាជាដុំកំភួន នៅក្នុងចំណោមអ្នកទោសទេ ។ ទោះជាយ៉ាងណាក៏ដោយ ក៏បច្ចុប្បន្ននេះ មានរបាយការណ៍ជាច្រើន អំពីឆ្មាំពន្ធនាគារ និងមន្ត្រីពន្ធនាគារដទៃទៀត បានផ្ទេរអំណាចខាងការដាក់វិន័យឱ្យទៅអ្នកទោសមួយចំនួនដែលពួកគេចូលចិត្ត ។ តាមធម្មតា អ្នកទោសម្នាក់ ឬច្រើននាក់ត្រូវបានចាត់ឱ្យមើលការខុសត្រូវតាមបន្ទប់ ហើយអ្នកទោសនោះប្រើប្រាស់តួនាទីនេះ ដើម្បីជរិតយកម្ហូបអាហារនិងសម្ភារៈប្រើប្រាស់ផ្សេងៗពីអ្នកទោសដទៃទៀត ព្រមទាំងសំរេចដាក់ទណ្ឌកម្មតាមអំពើចិត្តចំពោះការប្រព្រឹត្តបំពាន ដែលគេបានដឹង ។ ការប្រព្រឹត្តកំហុសតូចតាចដូចជា ការជជែកគ្នាក្រោយពេលថ្ងៃលិច  អាចនិងត្រូវទទួលការវាយដំ ហើយជាពិសេស អ្នកទោសចំណូលថ្មី គឺជាមុខសញ្ញានៃការវាយប្រហារជាប្រព័ន្ធ ។ នៅក្នុងករណីធ្ងន់ធ្ងរភាគច្រើន មន្ត្រីពន្ធនាគារបានណែនាំអ្នកទោសឱ្យធ្វើទណ្ឌកម្មចំពោះបទល្មើសធំៗ ដូចជាការរត់គេចខ្លួនចេញពីពន្ធនាគារ ។ ក្នុងឆ្នាំ១៩៩៨ នៅពន្ធនាគារខេត្តព្រៃវែង មានអ្នកទោសមួយក្រុមរួមទាំង "មេបន្ទប់ឃុំឃាំង" ផងដែរ បានវាយស្លាប់អ្នកទោសម្នាក់ក្នុងបន្ទប់ជាមួយគ្នា ហើយបានបង្ករបួសស្នាមធ្ងន់ធ្ងរ ដល់អ្នកទោសដទៃទៀត យ៉ាងតិចណាស់ក៏ ៤ នាក់ បន្ទាប់ពីមានការប៉ុនប៉ងរត់គេចចេញពីពន្ធនាគារនោះ ។ ឆ្មាំពន្ធនាគារត្រូវបានគេរាយការណ៍ថា មានវត្តមាននាពេលនោះដែរ ។

**ករណីសាកល្បង: ការជំនុំជំរះបទធ្វើទារុណកម្មនៅខេត្តកំពង់ចាម**

កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៩៩ មានអ្នកទោស៥ នាក់ នៅពន្ធនាគារខេត្តកំពង់ចាមបានលោតផ្លោះរបងក្នុងការព្យាយាមរត់គេចចេញពីគុក ប៉ុន្តែត្រូវបានចាប់ខ្លួនមកវិញនៅពេលភ្លាមៗនោះដែរ ហើយបាននាំខ្លួនត្រឡប់ទៅកាន់បរិវេណពន្ធនាគារវិញ ។ តាមការបំភ្លឺពីអ្នកទោសដទៃទៀត និងជនរងគ្រោះផ្ទាល់បានឱ្យដឹងថា នៅពេលនោះអ្នកទោសទាំង ៥ នាក់ ត្រូវឆ្មាំពន្ធនាគារវាយដំយ៉ាងធ្ងន់ធ្ងរ ។ មានការអះអាងថា ការវាយដំនេះធ្វើឡើងនៅចំពោះមុខមន្ត្រីពន្ធនាគារ រួមទាំងប្រធានពន្ធនាគារ និងមន្ត្រីពេទ្យពន្ធនាគារផងដែរ ហើយអ្នកទោសជាច្រើននាក់ផ្សេងទៀត បានឃើញហេតុការណ៍នេះយ៉ាងច្បាស់ ។ ការធ្វើបែបនេះគឺមានគោលបំណងដាក់ទណ្ឌកម្មផង

និងធ្វើឱ្យមានការរាងចាលផង ។ ជនរងគ្រោះទាំង ៥ នាក់នោះ ត្រូវបានគេវាយដំយ៉ាងច្រើន ដោយដងចបឬ កំណាត់ឈើ ហើយអ្នកខ្លះត្រូវគេដាល់ ទាត់ធាក់ ទះ ឬវាយក្បាលដោយជុំថ្ម ។

យ៉ាងតិចណាស់ក៏មានជនរងគ្រោះ ២ នាក់ដែរ បានអះអាងថា ខ្លួនត្រូវបានមន្ទីរព្យាបាលពន្ធនាគារ បដិសេធមិនទទួលព្យាបាលជម្ងឺ ម្នាក់មានរយៈពេល ២ ថ្ងៃ ហើយម្នាក់ទៀតមានរយៈពេល ១ សប្តាហ៍ ។ រយៈពេល២សប្តាហ៍បន្ទាប់ពីការវាយដំ ជនរងគ្រោះទាំង៥នាក់នោះត្រូវបានគេអះអាងថា ត្រូវគេដោះសំលៀក បំពាក់អស់ទុកតែខោក្នុង និងដកហូតយកកន្ទេល ភួយ និងមុង ។ អ្នកខ្លះបានអះអាងថា ត្រូវគេកាត់បន្ថយ របបម្ហូបអាហារ ហើយត្រូវបានគេដាក់ឱ្យនៅក្នុងបន្ទប់ឃុំឃាំង ២៤ ម៉ោងក្នុងមួយថ្ងៃ ដែលនេះគឺជាការរំលោភ លើបទបញ្ជាពន្ធនាគារ ហើយការរំលោភបែបនេះ កើតមានយ៉ាងតិចណាស់ក៏រយៈពេល ១ ខែ ដែរបន្ទាប់ពីការ វាយដំរួចមក ។ ការបង្អត់មិនឱ្យងូតទឹក បណ្តាលឱ្យអ្នកខ្លះកើតជំងឺសើរស្បែក ។ នៅពេលដែលអង្គការសិទ្ធិមនុស្ស ក្រៅរដ្ឋាភិបាល លីកាដូ បានធ្វើការសម្ភាសន៍មួយខែបន្ទាប់ពីការវាយដំ គេសង្កេតឃើញថាក្នុងចំណោមជន រងគ្រោះទាំង៥ នាក់ មានជនរងគ្រោះ ៤ នាក់ នៅតែមានដំបៅ និងស្នាមរបួសជាច្រើនកន្លែងនៅរាងកាយ ហើយ ជនរងគ្រោះម្នាក់ទៀតមានការលំបាកក្នុងការដើរ ។

ក្នុងខែ សីហា ឆ្នាំ២០០០ ឆ្មាំពន្ធនាគារ ៥ នាក់ ត្រូវបានចោទប្រកាន់ពីបទរំលោភលើសិទ្ធិបុគ្គល តាម មាត្រា៥៧ នៃច្បាប់អ៊ុនតាក់ ដែលហាមឃាត់ការធ្វើទារុណកម្ម និងការរំលោភផ្សេងៗទៅលើសិទ្ធិជនជាប់ឃុំឃាំង និងអ្នកទោស ។ បទល្មើសមជ្ឈឹមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំ ទៅ ៥ឆ្នាំ ។ ចាប់តាំងពីមានការចោទ ប្រកាន់មក យ៉ាងហោចណាស់ក៏មានឆ្មាំពន្ធនាគារ២នាក់ដែរ បានសុំលាឈប់ពីការងារ ។ ឆ្មាំពន្ធនាគារម្នាក់ បាន អះអាងនៅក្នុងកំណត់ហេតុសាកសួររបស់ចៅក្រមស៊ើបអង្កេតថា ខ្លួនបានធ្វើការវាយដំនេះតាមបញ្ជារបស់ ប្រធានពន្ធនាគារ ។ ជនសង្ស័យ ៣ នាក់ផ្សេងទៀត បានបន្តបំរើការងារជាឆ្មាំនៅពន្ធនាគារខេត្តកំពង់ចាម ជាដដែល ។ កាលនោះប្រធានពន្ធនាគារ មិនត្រូវបានតុលាការចោទប្រកាន់ទេ ហើយត្រូវបានធ្វើការផ្លាស់ប្តូរ ទៅកាន់មុខដំណែងថ្មី ។

ទោះបីជាពីដំបូង គេគ្រោងបើកសវនាការនៅចុងឆ្នាំ២០០១ និង មានសំណូមពរម្តងហើយម្តងទៀត ពីការិយាល័យសិទ្ធិមនុស្សអ.ស.បប្រចាំនៅកម្ពុជា និងក្រុមអង្គការសិទ្ធិមនុស្សដទៃទៀតក៏ដោយ ក៏នៅតែមិនមាន ការកំណត់កាលបរិច្ឆេទជាក់លាក់សំរាប់បើកសវនាការនេះដែរ ។ កាលពីខែមិថុនាឆ្នាំ២០០២ លោកតំណាងពិសេស បានជួបជាមួយប្រធាន និង ព្រះរាជអាជ្ញាអមតុលាការខេត្តកំពង់ចាម ហើយបានលើកឡើង អំពីបញ្ហាយឺតយ៉ាវ

ហួសពេលដ៏យូរមិនបើកសវនាការ ។ បន្ទាប់ពីការជួបពិភាក្សានេះមក តុលាការបានកំណត់ យកថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០២ សំរាប់បើកសវនាការ ។

នៅក្នុងពេលសវនាការ អ្នកសង្កេតការណ៍នៃការិយាល័យសិទ្ធិមនុស្សអ.ស.ប ប្រចាំនៅកម្ពុជា បាន កត់សំគាល់ឃើញថា ភស្តុតាងដែលបានបង្ហាញនៅក្នុងតុលាការ ពិតជាគ្រប់គ្រាន់អាចធ្វើការផ្តន្ទាទោសបាន ប៉ុន្តែតុលាការនៅតែសំរេចលើកលែងការចោទប្រកាន់ដល់ជនជាប់ចោទទាំង៥នាក់នោះ ។ ទោះបីជាដូច្នោះក្តី តុលាការបានបង្គាប់ឱ្យដាក់ទណ្ឌកម្មផ្នែករដ្ឋបាល ដល់ជនជាប់ចោទទាំងនោះ សេចក្តីសំរេចទំនងជាទទួលស្គាល់ ការទទួលខុសត្រូវរបស់ជនជាប់ចោទនៅក្នុងករណីនេះ ។ ចៅក្រមជំនុំជំរះមិនបានផ្តល់យុត្តិកម្មណាមួយ ទៅ លើសេចក្តីសំរេចនេះទេ ។ នៅខណៈពេលនោះដែរ ជនជាប់ចោទទាំង ៣ នាក់ ក្នុងចំណោមពួកគេ បន្តធ្វើការ ងារជាធម្មតានៅពន្ធនាគារនោះ ។

## ៥. ការគំរាមគំហែងដល់សិទ្ធិស្របច្បាប់របស់អ្នកទោស

### ការឃុំខ្លួនហួសនិតិវិធី

*"រយៈពេលឃុំឃាំងបណ្តោះអាសន្ន ទោះស្ថិតក្នុងករណីណាក៏ដោយ មិនត្រូវឱ្យហួសពីបួនខែទេ ។ ប៉ុន្តែតាមការសំរេច ដែលមានថែងមូលហេតុរបស់ចៅក្រម រយៈពេលនេះអាចបន្តដល់ប្រាំមួយខែ ប្រសិនបើ មានការចាំបាច់សំរាប់ស៊ើបអង្កេត..."*

មាត្រា ១៤.៤ នៃច្បាប់អ៊ុនតាក់

*របាយការណ៍ស្តីពីស្ថានភាពពន្ធនាគារនៅប្រទេសកម្ពុជា* បានរកឃើញថា ក្នុងឆ្នាំ១៩៩៤ មាន១៨% នៃអ្នកទោសដែលបានស្នង់មតិស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នលើសរយៈពេល៦ខែ ។ អ្នកទោស២នាក់ បាននិងកំពុងរង់ចាំសវនាការអស់រយៈពេល៩ឆ្នាំ ។ ទោះបីជាករណីហួសហេតុនេះត្រូវបានកាត់បន្ថយក៏ដោយ ក៏ការឃុំខ្លួនហួសនិតិវិធីនៅតែជាបញ្ហាធ្ងន់ធ្ងរ និងក្តៅគគុកនៅតំបន់មួយចំនួនក្នុងប្រទេស ។ រហូតមកទល់ថ្ងៃ ទី៣១ខែកក្កដា ឆ្នាំ២០០២ មានពិរុទ្ធជន ២០៥ នាក់ ត្រូវបានឃុំខ្លួនហួសនិតិវិធី នៅពន្ធនាគារ ៣ កន្លែងក្នុង ប្រទេសកម្ពុជា ( ១៥០នាក់ នៅមន្ទីរកែប្រែទី១, ៣៧ នាក់ នៅមន្ទីរកែប្រែទី២ និងមាន ១៨ នាក់ទៀតនៅ ពន្ធនាគារខេត្តបន្ទាយមានជ័យ) សរុបមានចំនួនប្រមាណជា ៣,៥% នៃចំនួនអ្នកទោសទាំងអស់នៅទូទាំង ប្រទេស ។ លើសពីនេះទៅទៀត បញ្ញត្តិដែលកំណត់រយៈពេលអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្ន ៤ ខែ ហើយអាចបន្តបានលើសពីនេះ ចំពោះករណីលើកលែងមួយចំនួន ជាធម្មតាគេមិនបានគោរពតាមនោះទេ

គឺកំណត់យកដោយគ្មានការកែប្រែ នូវរយៈពេល៦ខែ ធ្វើជានិយាម ។ មូលហេតុនៃការឃុំខ្លួនហួសនិតិវិធីរួមមានករណីរឿងច្រើនកកស្ទះនៅតុលាការ ការខ្វះមធ្យោបាយដឹកជញ្ជូននៅពន្ធនាគារ និងចៅក្រុមស៊ើបអង្កេតមានការយឺតយ៉ាវ ក្នុងការបញ្ចប់ការស៊ើបអង្កេត ។ បើតាមការអះអាងរបស់ព្រះរាជអាជ្ញា បានឱ្យដឹងថា ជារឿយៗនគរបាលទាមទារឱ្យធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ដោយមិនបានផ្តល់ភស្តុតាង គ្រប់គ្រាន់ឡើយ ដែលការនេះធ្វើឱ្យតុលាការមានការរារែកក្នុងការកំណត់កាលបរិច្ឆេទបើកសវនាការ ។

ចំនួនអ្នកជាប់ឃុំឃាំងបណ្តោះអាសន្ន មានការកើនឡើង ដោយគ្មានមេធាវីការពារ ជាពិសេសពន្ធនាគារនៅតាមបណ្តាខេត្តនានា ។ អ្នកទោសមួយចំនួនកំពុងរង់ចាំសេចក្តីសំរេចពីសវនាការ ដែលបានបើកជាយូរមកហើយ ។ ការិយាល័យសិទ្ធិមនុស្ស អ.ស.ប ប្រចាំនៅកម្ពុជា បានទទួលដំណឹងអំពីករណីមួយចំនួន ដែលអ្នកទោសបាននិងកំពុងរង់ចាំសេចក្តីសំរេចពីតុលាការ ក្នុងរឿងក្តីរបស់ខ្លួនអស់រយៈពេលជាងមួយឆ្នាំមកហើយ ។

### ការមិនបានដាក់ពិរុទ្ធជន និង ទណ្ឌិតឱ្យនៅដាច់ដោយឡែកពីគ្នា

បទបញ្ញត្តិជាបទដ្ឋានអប្បរមាសំរាប់ការគ្រប់គ្រងអ្នកទោសបានចែងថា ក្នុងគ្រប់ករណីទាំងអស់ "*ពិរុទ្ធជនត្រូវតែដាក់ឱ្យនៅដាច់ដោយឡែកពីទណ្ឌិត*"[១៧] ។ ការអនុវត្តន៍បែបនេះ មិនដែលមានទេនៅក្នុងប្រទេសកម្ពុជា ហើយចំនួនអ្នកជាប់ឃុំឃាំងបណ្តោះអាសន្នមានប្រមាណ ៣០ % នៃចំនួនអ្នកទោសទាំងអស់ត្រូវបានគេដាក់ឱ្យនៅលាយឡំគ្នាជាមួយទណ្ឌិត ។ កាលពីពេលថ្មីៗនេះ មានកិច្ចខិតខំប្រឹងប្រែងមួយធ្វើឡើងនៅពន្ធនាគារក្រុងព្រះសីហនុ ដើម្បីដាក់អ្នកទោសទាំងពីរក្រុមនេះ ឱ្យនៅដាច់ដោយឡែកពីគ្នា តែបច្ចុប្បន្នត្រូវបញ្ឈប់ទៅវិញ ដោយសារចំនួនអ្នកទោសមានការកើនឡើងច្រើន[១៨] ។

### អវត្តមាននៅពេលបើកសវនាការ

ដោយសារការខ្វះមធ្យោបាយដឹកជញ្ជូនអ្នកទោស ទើបជួនកាលពិរុទ្ធជនមិនអាចមកចូលរួមក្នុងសវនាការរបស់ខ្លួនបាន ។ ក្នុងករណីទាំងនេះ ជនជាប់ចោទត្រូវបានតុលាការបើកសវនាការ *ដោយកំបាំងមុខ* ដែលជាការរំលោភទៅលើសិទ្ធិជាមូលដ្ឋានរបស់ពួកគេ ក្នុងការទទួលបាននូវការជំនុំជំរះប្រកបដោយភាពត្រឹមត្រូវ ។ ជាងនេះទៅទៀត មានទណ្ឌិតជាច្រើននាក់ ជាពិសេសនៅតំបន់ដាច់ស្រយ៉ាលមួយចំនួន ត្រូវបានគេរាយការណ៍ថា មិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទបើកសវនាការនៅសាលាឧទ្ធរណ៍ និងតុលាកាកំពូលឡើយ ។ នៅក្នុងករណីភាគច្រើន

---

[១៧] បទបញ្ញត្តិជាបទដ្ឋានអប្បរមាសំរាប់ការគ្រប់គ្រងអ្នកទោស ចំណុច ៨

[១៨] របាយការណ៍តាមកាលកំណត់ ស្តីពីពន្ធនាគាររបស់ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ខែមីនា ឆ្នាំ២០០២ ។

អ្នកទោសទាំងនេះ ឬគ្រួសាររបស់គេត្រូវបានស្នើឱ្យចេញថ្លៃធ្វើដំណើរផ្ទាល់ខ្លួន និងថ្លៃឈ្នួលអ្នកយាមពីពន្ធនាគារ ដែលឃុំខ្លួនពួកគេឆ្ពោះទៅរាជធានីភ្នំពេញ។ ថ្លៃឈ្នួលទាំងនេះ គួរតែជាបន្ទុករបស់ពន្ធនាគារជាអ្នកទទួលខុសត្រូវលើការចេញចំណាយ ដែលតំលៃនោះអាចច្រើនជាង ១០០ ដុល្លារអាមេរិក សំរាប់ការធ្វើដំណើរពីខេត្តឆ្ងាយៗ។

## ការចូលរួមសវនាការក្នុងសំលៀកបំពាក់ជាអ្នកទោស

អ្នកទោសដែលគេបញ្ជូនទៅតុលាការ ជារឿយៗស្ថិតក្នុងសំលៀកបំពាក់ជាអ្នកទោស ដែលនេះគឺជាការរំលោភលើគោលការណ៍នៃការសន្មត់ជាមុនថាគ្មានទោស។ នៅក្នុងឆ្នាំ២០០១ ប្រធាននាយកដ្ឋានពន្ធនាគារ បានចេញសេចក្តីណែនាំមួយជាលាយលក្ខអក្សរ ផ្ញើរជូនប្រធានពន្ធនាគារទាំងអស់ ស្តីពីការផ្តល់សំលៀកបំពាក់ស៊ីវិលឱ្យអ្នកទោស។ ទោះជាយ៉ាងណាក៏ដោយ សេចក្តីណែនាំនេះ នៅមិនទាន់បានអនុវត្តនៅក្នុងករណីភាគច្រើន។

## ការឃុំឃាំងរយៈពេលគ្មានកំណត់រង់ចាំសវនាការនៅសាលាឧទ្ធរណ៍

អ្នកទោសត្រូវតែស្ថិតនៅក្នុងពន្ធនាគារ រង់ចាំសវនាការនៅសាលាឧទ្ធរណ៍ ទោះបីជាបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយព្រះរាជអាជ្ញា ឬដោយអ្នកទោសខ្លួនឯងក្តី។ ដោយសារសវនានៅសាលាឧទ្ធរណ៍អូសបន្លាយពេលវេលាវែងពេក ទើបមានអ្នកទោសជាច្រើន ដែលករណីរបស់ខ្លួនជាប់បណ្តឹងឧទ្ធរណ៍ នៅតែបន្តជាប់ឃុំឃាំងទោះបីជាទោសរបស់ខ្លួនត្រូវបានបំពេញចប់សព្វគ្រប់ហើយក៏ដោយ។ នេះជាបញ្ហាចំបងដែលធ្វើឱ្យអ្នកទោសមានការរារែកក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ហើយនៅក្នុងករណីខ្លះបញ្ហានេះបានជំរុញឱ្យអ្នកទោស ព្យាយាមដកបណ្តឹងឧទ្ធរណ៍របស់ខ្លួនវិញ ដើម្បីបានចាកចេញពីពន្ធនាគារ។

## ការមិនគោរពបទបញ្ជាពន្ធនាគារ

នាយកដ្ឋានពន្ធនាគារ ចេញបទបញ្ជាដោយឡែកជាច្រើន ទៅកាន់ពន្ធនាគារផ្សេងៗគ្នា នៅទូទាំងប្រទេសកម្ពុជា រីឯប្រធានពន្ធនាគារក៏ចេញនូវបទបញ្ញត្តិផ្ទាល់ខ្លួនផងដែរ។ ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បានរកឃើញថា ផ្នែកខ្លះនៃបទបញ្ញត្តិទាំងនោះ មិនស្របតាមបទដ្ឋានអន្តរជាតិ ឬប្រកាស និងនិតិវិធីពន្ធនាគារនោះទេ។ ជាឧទាហរណ៍ប្រការ ៩ នៃបទបញ្ជាពន្ធនាគារ CC1 ផ្តល់សិទ្ធិឱ្យប្រធានពន្ធនាគារប្រើប្រាស់អាវុធនៅពេលណា ដែលគាត់យល់ថា ជាស្ថានភាពចាំបាច់។ ប្រការនេះ មានភាពមិនស្របគ្នាជាមួយប្រកាសលេខ ២១៧ (ស្តីពីការគ្រប់គ្រងពន្ធនាគារ) ដែលចែងអំពីកាលៈទេសៈពិសេសមួយចំនួន ដែល

គេអនុញ្ញាតឱ្យប្រើប្រាស់អាវុធបាន[១៩] ។ មានការខ្វះខាតផងដែរ នូវការអនុវត្តន៏សេចក្តីណែនាំរបស់ក្រសួងពាក់ព័ន្ធដែលទាក់ទងនឹងបញ្ហាពន្ធនាគារ ។ សេចក្តីណែនាំ ឬបទបញ្ជាមួយចំនួនចេញដោយថ្នាក់ក្រសួងទៅអាជ្ញាធរពន្ធនាគារ ឬមន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធ ប៉ុន្តែជាក់ស្តែងគេកម្រឃើញមានការអនុវត្តន៏តាមណាស់ ។

## ៦_ការចូលសួរសុខទុក្ខអ្នកទោសនៅក្នុងពន្ធនាគារ

លោកតំណាងពិសេស ការិយាល័យសិទ្ធិមនុស្សអ.ស.បប្រចាំនៅកម្ពុជា និងអង្គការសិទ្ធិមនុស្សក្រៅរដ្ឋាភិបាលក្នុងស្រុកជាច្រើន បានសំដែងនូវកង្វល់របស់ខ្លួន អំពីនិតិវិធីគ្រប់គ្រងការចូលសួរសុខទុកអ្នកទោសនៅក្នុងពន្ធនាគារ ។ ទស្សនកិច្ចទៅកាន់ពន្ធនាគារ ត្រូវបានគេចែកចេញជាបីប្រភេទធំគឺះ

### ការសួរសុខទុក្ខដោយក្រុមគ្រួសារអ្នកទោស

*របាយការណ៏ស្តីពីស្ថានភាពពន្ធនាគារនៅប្រទេសកម្ពុជា* បានរកឃើញថា ការស្ទង់មតិបានកំណត់ជាមធ្យមភាគ គឺមានការចូលសួរសុខទុកអ្នកទោស ២ ដងក្នុងមួយខែសំរាប់អ្នកទោសម្នាក់ៗ ។ ការសួរសុខទុក្ខអ្នកទោសពីក្រុមគ្រួសារ និងមិត្តភ័ក្ត គឺជាការសំខាន់ខ្លាំងណាស់សំរាប់អ្នកទោស មិនត្រឹមតែជាជំនួយខាងផ្លូវចិត្តប៉ុណ្ណោះទេ ថែមទាំងជួយផ្តល់ម្ហូបអាហារ និងសំភារៈចាំបាច់ផ្សេងទៀត និងជួយឱ្យពួកគេវិលត្រឡប់មករួមរស់នៅក្នុងសង្គមវិញ នៅពេលបានបំពេញទោសចប់សព្វគ្រប់ ។ ច្បាប់តម្រូវថា អ្នកទោសគ្រប់រូបមានសិទ្ធិទទួលបានការសួរសុខទុក្ខពីក្រុមគ្រួសារ ឬមិត្តភ័ក្ត រយៈពេលមួយម៉ោងជាអប្បបរមាក្នុងមួយសប្តាហ៏[២០] ។ បញ្ញត្តិនេះត្រូវបានមើលរំលងជាប្រព័ន្ធ ។ តាមការអនុវត្តជាក់ស្តែង ក្រុមគ្រួសារអ្នកទោសភាគច្រើនអាចបានចូលសួរសុខទុក្ខ ច្រើនជាង ១៥ នាទីបន្តិចក្នុងមួយសប្តាហ៏ ។ ការចូលសួរសុខទុក្ខអ្នកទោសរិតតែមានការលំបាកថែមទៀត ចំពោះក្រុមគ្រួសារដែលមានសាច់ញាតិជាប់ឃុំឃាំងនៅពន្ធនាគារ ឆ្ងាយពីលំនៅដ្ឋានរបស់ខ្លួន ។ ស្ថានភាពបែបនេះ កើតមានជាទូទៅៗហើយ ពីព្រោះអ្នកទោសត្រូវបានគេបញ្ជូនទៅកាន់ពន្ធនាគារផ្សេងៗនៅទូទាំងប្រទេស ក្នុងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយបញ្ហាដាក់អ្នកទោសច្រើនហួសចំណុះ នៅក្នុងពន្ធនាគារមួយចំនួន ។

---

[១៩] ប្រកាសលេខ២១៧ (ស្តីពីការគ្រប់គ្រងពន្ធនាគារ) មាត្រា ៧Bចែងថា "មិនត្រូវប្រើប្រាស់អាវុធ លើកលែងតែក្នុងករណីមិនអាចជៀសវាងបាន ដូចជាក្នុងកិច្ចស្វ័យការពារ ឬកិច្ចការផ្សេងទៀតដែលស្ថិតក្នុងកាលៈទេសៈ ដូចតទៅនេះ : ក្នុងករណីមានការគំរាមកំហែងដល់អាយុជីវិត ឬរបួសធ្ងន់ធ្ងរ ដើម្បីទប់ស្កាត់បទល្មើសធ្ងន់ធ្ងរពាក់ព័ន្ធ នឹងការគំរាមកំហែងដល់អាយុជីវិត ដើម្បីទប់ស្កាត់ការរត់គេចខ្លួនក្នុងករណីដែលការប្រើប្រាស់មធ្យោបាយតិចតួច មិនអាចធ្វើទៅបាន និងក្នុងការការពារជនណាម្នាក់ ដែលទទួលការគំរាមកំហែងដល់អាយុជីវិត បង្កឡើងដោយអ្នកទោសដែលកំពុងរត់គេចខ្លួន" ។

[២០] ប្រកាសលេខ ២១៧ (ស្តីពីការគ្រប់គ្រងពន្ធនាគារ) មាត្រា ៧B ។

ទោះបីជាអាចទៅដល់ពន្ធនាគារនោះក៏ដោយ ក៏នៅមានការលំបាកជាច្រើនដែរ ។ ពន្ធនាគារខ្លះ មិនមានទីកន្លែងសមរម្យសំរាប់ក្រុមគ្រួសារអ្នកទោស ហើយការសួរសុខទុក្ខធ្វើឡើងនៅរោងបាយ ឬមន្ទីរព្យាបាលរបស់ពន្ធនាគារ ។ នៅក្នុងឆ្នាំ១៩៩៤ មានពន្ធនាគារជាច្រើនបដិសេធជាញឹកញាប់ នូវសិទ្ធិចូលសួរសុខទុក្ខពីក្រុមគ្រួសារ ថាជាវិធានការដាក់វិន័យដល់អ្នកទោស ។ បញ្ហាដែលធ្ងន់ធ្ងរបំផុតនោះ គឺមានការកើនឡើង ចាប់តាំងពីឆ្នាំ១៩៩៤ នូវអំពើពុករលួយពាក់ព័ន្ធទៅនឹងការចូលសួរសុខទុក្ខពីក្រុមគ្រួសារអ្នកទោស ។ ឆ្មាំ និងមន្ត្រីពន្ធនាគារ ជារឿយៗ បានសុំឱ្យក្រុមគ្រួសារអ្នកទោសបង់ប្រាក់ជាថ្នូរនឹងការអនុញ្ញាតឱ្យចូលសួរសុខទុក្ខ ។ តាមធម្មតា គេទាមទារឱ្យបង់ប្រាក់យ៉ាងច្រើន នៅពេលចូលសួរសុខទុក្ខអ្នកទោសលើកដំបូង និងការចូលសួរសុខទុក្ខអ្នកទោសនៅថ្ងៃដែលគ្មានការអនុញ្ញាតជាផ្លូវការ ។ អំពើពុករលួយកើតមានផងដែរ នៅពេលដែលក្រុមគ្រួសារមានបំណងផ្ញើរទៅឱ្យអ្នកទោសនូវម្ហូបអាហារ ទឹក ថ្នាំពេទ្យ និងសំភារៈចាំបាច់ផ្សេងទៀត ។

## ការចូលជួបអ្នកទោសដោយមេធាវីការពារក្តី

នៅក្នុងឆ្នាំ១៩៩៤ ពន្ធនាគារខ្លះខ្វះទីកន្លែងសមរម្យសំរាប់មេធាវីការពារក្តី ដើម្បីជួបកូនក្តីរបស់ខ្លួន ដែលនាំឱ្យអ្នកទោសមិនមានទំនុកចិត្តទៅលើការសំងាត់របស់ខ្លួននៅក្នុងការពិគ្រោះយោបល់ ។ មេធាវីការពារក្តី ក៏បានត្អូញត្អែរផងដែរថា មន្ត្រីពន្ធនាគារតែងតែរារាំងដល់ការចូលជួបកូនក្តីរបស់ខ្លួន ការដាក់កំហិតពេលវេលា ឬការតម្រូវឱ្យសុំការអនុញ្ញាតបន្ថែមពីក្រសួងមហាផ្ទៃ ។

## ទស្សនកិច្ចទៅកាន់ពន្ធនាគារ ដោយអង្គការសហប្រជាជាតិ និងអង្គការក្រៅរដ្ឋាភិបាល

ការិយាល័យសិទ្ធិមនុស្ស អ.ស.ប ប្រចាំនៅកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាល បាននិងកំពុងជួបប្រទះការលំបាកយ៉ាងខ្លាំង និងច្រើនថែមទៀត ក្នុងការសុំការអនុញ្ញាតចូលសួរសុខទុក្ខអ្នកទោស និងការចូលពន្ធនាគារនៅក្នុងករណីមួយចំនួន ។ ស្ថានភាពពីពន្ធនាគារមួយ ទៅពន្ធនាគារមួយទៀត មានភាពខុសគ្នាយ៉ាងខ្លាំង ដោយការចូលពន្ធនាគារខ្លះ មានការកំណត់យ៉ាងតឹងតែងទាំងលក្ខខណ្ឌ ទាំងពេលវេលាដែលអនុញ្ញាត និងអាចចូលពិនិត្យតាមបន្ទប់ឃុំឃាំងបាន ។ ការចូលជួបអ្នកជាប់ឃុំឃាំងបណ្តោះអាសន្ន អាចអនុញ្ញាតទៅបាន លុះត្រាតែមានលិខិតអនុញ្ញាតជាលាយលក្ខអក្សរពីចៅក្រម ឬព្រះរាជអាជ្ញាពាក់ព័ន្ធ ហើយដែលលិខិតនោះ គេពិបាកទាក់ទងសុំខ្លាំងណាស់ ។ បើតាមសេចក្តីរាយការណ៍ គឺខ្វះកិច្ចសហប្រតិបត្តការពីសំណាក់មន្ត្រីពន្ធនាគារមួយចំនួន ឧទាហរណ៍ ដូចជានៅខេត្តស្វាយរៀង ។ គេមិនអនុញ្ញាតឱ្យធ្វើសម្ភាសន៍ដោយផ្ទាល់ជាមួយអ្នកទោសឡើយ ដែលជាហេតុនាំឱ្យមានការលំបាកជាខ្លាំងក្នុងការប្រមូលពតិមានដែលអាចជឿទុកចិត្តបាន អំពីការធ្វើទុក្ខទោស និងការធ្វើទារុណកម្មដោយមន្ត្រីប្រតិបត្តិច្បាប់និងមន្ត្រីពន្ធនាគារ ។

## ៧. អនុសាសន៍

**ចំនួនអ្នកទោសច្រើនហួសចំណុះ**

- ចាត់វិធានការជាបន្ទាន់ ដើម្បីកាត់បន្ថយចំនួនអ្នកជាប់ឃុំឃាំងជាបណ្តោះអាសន្ន តាមរយៈការពន្លឿននីតិវិធីតុលាការ ។
- ធានាថាមិនត្រូវធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយឡើយ ប្រសិនបើគ្មានភស្តុតាងគ្រប់គ្រាន់អាចធ្វើការជំនុំជំរះបាន ។
- ប្រតិបត្តិច្បាប់អ៊ុនតាក់មាត្រា១៤.១ ដែលចែងថា ជនជាប់ចោទអាចត្រូវបានបញ្ជូនទៅឃុំឃាំងជាបណ្តោះអាសន្ន តែក្នុងលក្ខខណ្ឌជាក់លាក់ប៉ុណ្ណោះ ។
- ប្រតិបត្តិច្បាប់អ៊ុនតាក់ មាត្រា១៤.៤ ដែលចែងថា ការឃុំឃាំងជាបណ្តោះអាសន្ន ទោះស្ថិតក្នុងករណីណាក៏ដោយមិនត្រូវឱ្យហួសពី ៤ ខែ ទេ ប៉ុន្តែរយៈពេលនេះអាចបន្តដល់ ៦ ខែតែក្នុងកាលៈទេសៈពិសេសតែប៉ុណ្ណោះ ។
- ធានាថា ប្រធានពន្ធនាគារបំពេញនូវការទទួលខុសត្រូវរបស់ខ្លួន ក្នុងការជូនដំណឹងទៅតុលាការអំពីការផុតរយៈពេលឃុំខ្លួនបណ្តោះអាសន្ន ។
- បង្កើតឱ្យមានសាលាឧទ្ធរណ៍ថ្នាក់តំបន់ ឬសាលាឧទ្ធរណ៍ចល័ត ។
- បញ្ជាក់អំពីការពិន័យជាប្រាក់ និងការព្យួរទោស ។
- ពិនិត្យទៅលើមធ្យោបាយផ្សេង ដែលជាជំរើសសំរាប់ការដាក់ទណ្ឌកម្ម ហើយពិចារណាឡើងវិញទៅលើរយៈពេលនៃទោសជាប់ពន្ធនាគារ សំរាប់បទល្មើសតូចតាច ។
- ស្រាវជ្រាវពីលទ្ធភាពបង្កើតបទបញ្ជាសេវាសហគមន៍ ដែលអាចប្រើប្រាស់បានសំរាប់បទល្មើសតូចតាច និងអ្នកប្រព្រឹត្តបទល្មើសលើកដំបូង ហើយនិងអប់រំដល់សាធារណៈជនអំពីការអនុវត្តន៍ទោសនៅក្រៅពន្ធនាគារ ។
- ជំនួសឱ្យកម្មវិធីនៃការដោះលែងមុនរយៈពេលកំណត់ដែលអនុវត្តនាបច្ចុប្បន្ននេះ ដោយគំរោងការតាក់តែងច្បាប់ដ៏ទូទូលាយមួយ ។
- ផ្តល់អាទិភាពដល់ការងារសាងសង់ និងជួសជុលកែលំអរឡើងវិញ នូវពន្ធនាគារក្រុងព្រះសីហនុ កំពង់ធំ និងបន្ទាយមានជ័យ ។

### ម្ហូបអាហារនិងទឹក

- គ្រប់គ្រងចាត់ចែងថវិកាឱ្យបានល្អប្រសើរឡើងថែមទៀត ដើម្បីធានាថា មិនមានការដកយកថវិកាសំរាប់អាហារឧបត្ថម្ភអ្នកទោស ទៅចំណាយលើសំភារៈ ឬសេវាផ្សេងៗទៀតឡើយ ហើយត្រូវត្រួតពិនិត្យមើលដើម្បីថានាថា របបអាហារដែលមានតំលៃអប្បរមា ១000 រៀល បានដល់អ្នកទោសម្នាក់ៗរៀងរាល់ថ្ងៃដោយមិនត្រូវឱ្យបាត់បង់ទៅលើអំពើពុករលួយឡើយ ។
- បញ្ជាក់យ៉ាងច្បាស់ថា ការដាក់កំហិតទៅលើអាហារឧបត្ថម្ភ សំរាប់ជាវិធានការដាក់ទណ្ឌកម្មនោះ គឺមិនត្រូវបណ្តោយឱ្យធ្វើតទៅទៀតជាដាច់ខាត ។ ហើយត្រូវចាត់វិធានខាងវិន័យ ចំពោះមន្ត្រីពន្ធនាគារណាដែលប្រព្រឹត្តិបទល្មើស ។
- ធានាផ្តល់ឱ្យបានទៀងទាត់នូវទឹកស្អាតសំរាប់ផឹក នៅគ្រប់ពន្ធនាគារទាំងអស់ ដោយផ្តល់អាទិភាពឱ្យពន្ធនាគារខេត្តបន្ទាយមានជ័យ ខេត្តព្រះវិហារ និងក្រុងព្រះសីហនុ ។

### សុខភាព និងសេវាពេទ្យ

- ធ្វើការបញ្ជាក់បំភ្លឺ តាមរយៈប្រកាសអន្តរក្រសួង ស្តីពីការទទួលខុសត្រូវ សំរាប់បញ្ហាសុខភាពអ្នកទោសរវាងក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល ។
- ធានាថាប្រាក់ដែលត្រូវចំណាយទៅលើអ្នកទោស និងប្រាក់ឧបត្ថម្ភផ្សេងៗ ត្រូវបានទទួលទាន់ពេលវេលានិងគ្រប់ចំនួនតាមរយៈការផ្ទេរដោយផ្ទាល់ពីនាយកដ្ឋានហិរញ្ញវត្ថុក្រសួងមហាផ្ទៃ ទៅរតនាគារតាមខេត្ត ។
- ជួសជុលកែលំអរផ្នែកអាគារពន្ធនាគារនៃមន្ទីរពេទ្យមុនីវង្ស ដោយបំពាក់ឧបករណ៍អនាម័យឱ្យបាន សមរម្យ ។
- បង្កើតគោលនយោបាយសំរាប់អ្នកទោសដែលមានជម្ងឺអេដស៍ និងលើកលែងទោសដល់អ្នកកើតជំងឺអេដស៍ទាំងឡាយណា ដែលស្ថិតក្នុងស្ថានភាពចុងក្រោយនៃជំងឺអេដស៍ ។

### រដ្ឋបាលពន្ធនាគារ

- ធានាថា ពន្ធនាគារត្រូវមានថវិកាគ្រប់គ្រាន់ និងស្របទៅតាមគំរោងជាពិសេសតាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការ រវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់មន្ត្រី និងឆ្មាំពន្ធនាគារ ផ្តល់ប្រាក់បៀវត្សរ៍សមស្រប អាចឱ្យគេផ្គត់ផ្គង់ជីវភាពរស់នៅ និងកន្លែងស្នាក់នៅសមរម្យ ។
- ធានាថា បុគ្គលិករដ្ឋបាលនៃពន្ធនាគារនីមួយៗ មានចំនួនសមាមាត្រទៅនិងចំនួនអ្នកទោស ។
- ធានាការផ្តល់ឱ្យមានឆ្មាំពន្ធនាគារជាស្ត្រី សំរាប់អ្នកទោសស្ត្រី ។

- កំណត់អាទិភាពដល់ការដឹកជញ្ជូនអ្នកទោស ដោយផ្តល់តាមសេចក្តីត្រូវការនូវប្រេងឥន្ធនៈ និងប្រាក់ឧបត្ថម្ភសំរាប់ការធ្វើដំណើរ ។

## ការគំរាមកំហែងដល់សុវត្ថិភាព

- ពង្រឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីដាក់អ្នកទោសទៅតាម ភេទ អាយុ (ក្មេង ឬ មនុស្សពេញវ័យ) ឋានៈខាងផ្លូវច្បាប់ (ពិរុទ្ធជន ឬទណ្ឌិត ) ភាពធ្ងន់ធ្ងរនៃបទល្មើស និងស្ថានភាពខាងសុខភាព ។
- នាំមកកាត់ទោសជនទាំងឡាយណា ដែលត្រូវបានគេចោទប្រកាន់ថាបានធ្វើទារុណកម្ម ហើយត្រូវធានាថាតុលាការអាចធ្វើសេចក្តីសំរេច ដោយសេរីគ្មានការគាបសង្កត់ពីរដ្ឋាភិបាល ។
- គោរពបញ្ញត្តិច្បាប់ទាក់ទងនិងការប្រើប្រាស់ឧបករណ៏ទប់ទល់នឹងអ្នកទោស ដោយធានាថា ខ្នោះដៃត្រូវបានប្រើប្រាស់តែក្នុងពេលដឹកបញ្ជូនអ្នកទោស ឬក្នុងស្ថានភាពបន្ទាន់ណាមួយ ហើយការប្រើប្រាស់ខ្នោះជើង ត្រូវតែលប់បំបាត់ចោល ។
- ហាមប្រើប្រាស់អ្នកទោសដែលខ្លួនចូលចិត្ត និង "មេបន្ទប់" ។

## សិទ្ធិខាងផ្លូវច្បាប់

- បង្កើនកិច្ចសហប្រតិបត្តិការ រវាងក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ។
- ធានាថាអ្នកទោសត្រូវបានផ្តល់ឱ្យនូវសំលៀកបំពាក់ស៊ីវិលនៅពេលបង្ហាញខ្លួននៅតុលាការ ។
- ទប់ស្កាត់ការបើកសវនាការកំបាំងមុខ ចំពោះអ្នកទោសដែលស្ថិតនៅក្នុងមន្ទីរឃុំឃាំង ហើយមិនអាចមកចូលរួមសវនាការបាន ដោយសារខ្វះមធ្យោបាយដឹកជញ្ជូន ។
- ដោះលែងជាបន្ទាន់ អ្នកទោសដែលកំពុងរង់ចាំសវនាការនៅសាលាឧទ្ធរណ៏ ហើយដែលបានបំពេញទោសចប់សព្វគ្រប់ហើយ ។

## បទបញ្ញត្តិ និងបទបញ្ជា

- ធ្វើការតែងតាំងអ្នកជំនាញការច្បាប់មួយក្រុម ដើម្បីពិនិត្យឡើងវិញ នូវច្បាប់ពន្ធនាគារទាំងអស់របស់កម្ពុជាដូចជាប្រកាស នីតិវិធី និងបទបញ្ញត្តិនានា ដើម្បីឱ្យស្របតាមច្បាប់ពាក់ព័ន្ធ ដែលមានឋានានុក្រមខ្ពស់ជាង និងស្របតាមបទដ្ឋានអន្តរជាតិ ដោយមានការចូលរួមផ្តល់មតិពីអង្គការក្រៅរដ្ឋាភិបាល និងអង្គការផ្សេងៗ ដែលធ្វើការក្នុងវិស័យពន្ធនាគារ ។
- ធ្វើការកែប្រែច្បាប់ និងបទបញ្ជាពន្ធនាគារពាក់ព័ន្ធ និងដកចេញនូវរាល់បទបញ្ជាណាដែលផ្ទុយនឹងច្បាប់ ។

- តាមដានមើលការអនុវត្តន៍ បន្ទាប់ពីបានចេញបទបញ្ជា និងធ្វើទស្សនកិច្ចទៅកាន់ពន្ធនាគារនីមួយៗ ដើម្បីធានាថា បទបញ្ជានិងច្បាប់ ត្រូវបានយល់ដឹងយ៉ាងច្បាស់ និងគោរពតាម ។

## ការចូលសួរសុខទុក្ខអ្នកទោស

- ចាត់វិធានការជាបន្ទាន់ និងមានប្រសិទ្ធភាព ដើម្បីបញ្ឈប់អំពើពុករលួយក្នុងប្រព័ន្ធពន្ធនាគារ ។
- ខិតខំប្រឹងប្រែងអស់ពីលទ្ធភាព ដើម្បីធានាថា អ្នកទោសត្រូវបានឃុំឃាំង នៅទីកន្លែងឃុំឃាំង ដែលនៅជិតលំនៅដ្ឋាន និងគ្រួសាររបស់គេបំផុត ។
- អនុញ្ញាតឱ្យអ្នកឃ្លាំមើលពន្ធនាគារ ធ្វើបទសម្ភាសន៍ជាឯកជន ជាមួយអ្នកទោស ដោយមានការសង្កេតមើលពីចំងាយ តែមិនអាចស្តាប់ឮបានពីមន្ត្រីពន្ធនាគារ ( សូមអានមាត្រា៧.១ និតិវិធី ពន្ធនាគារលេខ២៩) ។
- គាំទ្រដល់ការអនុម័តពង្រាងពិធីសារបន្ថែមរបស់អង្គការសហប្រជាជាតិលើអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តិទាំងឡាយណា ដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តំលៃជាមនុស្ស និងផ្តល់សច្ចាប័នលើការអនុម័តនេះ ។